00274009

C20/5/7

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 22 / 01 / 2009
ម៉ោង (Time/Heure): 16:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: C. A. Fu

# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

## នៅចំពោះមុខអង្គបុរេជំនុំជម្រះ

| | | |
|---|---|---|
| សំណុំរឿងលេខ | ៖ | ០០២/១៩-០៩-២០០៧-អ.វ.ត.ក/[illegible] ០៦) |
| បញ្ជូនទៅ | ៖ | អង្គបុរេជំនុំជម្រះ |
| កាលបរិច្ឆេទឯការ | ៖ | ថ្ងៃទី២២ ខែមករា ឆ្នាំ២០០៩ |
| ភាគីបញ្ជូន | ៖ | ការិយាល័យសហព្រះរាជអាជ្ញា |
| ភាសាដើម | ៖ | អង់គ្លេស |
| ប្រភេទឯកសារ | ៖ | សាធារណៈ: (អត្ថបទត្រូវបានលុបចោលខ្លឹមសារមួយចំនួន) |

---

**អត្ថបទត្រូវបានលុបចោលខ្លឹមសារមួយចំនួន នៃចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹងបណ្តឹងឧទ្ធរណ៍របស់មេធាវីការពារក្តី អៀង ធីរិទ្ធ ប្រឆាំងនឹង “ដីកាសម្រេច អំពីការបន្តថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០០៨”**

---

**បញ្ជូនដោយ៖**

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោកស្រី ជា លាង

លោក Robert PETIT

លោក យ៉េត ចរិយា

លោក William SMITH

លោក សេង ប៊ុនឃាង

លោក Vincent de WILDE d'ESTMAEL

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 26 / 01 / 2009
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: C. A. Fu

**ចែកចាយជូន៖**

**អង្គបុរេជំនុំជម្រះ៖**

ចៅក្រម ប្រាក់ គឹមសាន

ចៅក្រម ន័យ ថុល

ចៅក្រម ហួត វុទ្ធី

ចៅក្រម Katinka LAHUIS

ចៅក្រម Rowan DOWNING

**មេធាវីការពារក្តីរបស់ អៀង ធីរិទ្ធ៖**

លោក ផាត់ ពៅស៊ាង

លោកស្រី Diana ELLIS

## ១. សេចក្ដីផ្ដើម

១. សហព្រះរាជអាជ្ញាឆ្លើយតបទៅនឹងបណ្ដឹងឧទ្ធរណ៍របស់មេធាវីការពារក្ដី (“បណ្ដឹងឧទ្ធរណ៍”) ដែលបានដាក់កាលពីថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០០៨ ស្របតាមវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក (“វិធានផ្ទៃក្នុង”) វិធាន៧៤.ច និងវិធាន៧៥ ។ បណ្ដឹងឧទ្ធរណ៍ស្នើដល់អង្គបុរេជំនុំជម្រះ (“អ.ប.ជ”) ច្រានចោល សេចក្ដីសម្រេចរបស់សហចៅក្រមស៊ើបអង្កេត អំពីការបន្តថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្ន (“ដីកាសម្រេចបន្តការឃុំខ្លួន”) អៀង ធីរិទ្ធ (“ជនត្រូវចោទ” ឬ “ដើមបណ្ដឹងឧទ្ធរណ៍”) និងសុំឲ្យដោះលែងគាត់ជាបន្ទាន់ ស្របតាមលក្ខខណ្ឌសមស្របនានា[1] ។ មេធាវីការពារក្ដីតវ៉ាថា សហចៅក្រមស៊ើបអង្កេត (“ស.ច.ស”) បានធ្វើឲ្យមានកំហុសជាច្រើនទាំងខាងផ្នែកអង្គហេតុ និងអង្គច្បាប់ នៅក្នុងដីកាសម្រេចបន្តការឃុំខ្លួន។ មេធាវីការពារក្ដីអះអាងថា (១) ដីកាសម្រេចបន្តការឃុំខ្លួន ធ្វើឡើងដោយមិនមានហេតុផល គ្រប់គ្រាន់ទេ (២) ស.ច.ស បានប្រើប្រាស់បទដ្ឋាននានាដោយខុស នៅក្នុងន័យនៃការយកចិត្តទុកដាក់ និងភស្តុតាងនានាដែលរកបាន (៣) ស.ច.ស បានធ្វើឲ្យខូចដល់សិទ្ធិនៅស្ងៀម មិនឆ្លើយតបរបស់ដើមបណ្ដឹងឧទ្ធរណ៍ (៤) ដីកាសម្រេចបន្តការឃុំខ្លួន មិនបានបញ្ជាក់ពី “ហានិភ័យ” ណាមួយដែលថា សាក្សីនានាអាចនឹងបដិសេធចូលរួមនៅក្នុងកិច្ចដំណើរការនីតិវិធីនៅពេលអនាគត បើសិនជនត្រូវចោទត្រូវបានដោះលែងនោះ - វិធាន៦៣.៣.ខ.ឈ ។

២. សហព្រះរាជអាជ្ញា សន្និដ្ឋានថា ពាក្យសុំរបស់មេធាវីការពារក្ដីកំពុងស្វែងរកឲ្យមានការកែប្រែដីកាសម្រេចបន្តការឃុំខ្លួនរបស់ ស.ច.ស និងការដោះលែងជាបន្ទាន់ គួរតែត្រូវបានបដិសេធទាំងស្រុង ដោយឈរលើមូលហេតុដូចតទៅ ៖

---

[1] *ករណីរបស់ អៀង ធីរិទ្ធ,* បណ្ដឹងឧទ្ធរណ៍របស់មេធាវីការពារក្ដីអៀង ធីរិទ្ធ ប្រឆាំងនឹង “ដីកាសម្រេចអំពីការបន្តថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្ន” ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០០៨, ចុះកាលបរិច្ឆេទថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០០៨, C 20/5/1, ERN 00250142-63 (ភាសាអង់គ្លេស) ។

C20/5/7



(ក) ដីកាសម្រេចបន្តការឃុំខ្លួន ធ្វើដោយ ស.ច.ស គឺមានលក្ខណៈគ្រប់គ្រាន់ និងសមល្មម៖ ស.ច.ស បានដាក់ចេញដោយលើកយកមកពិចារណាអំពីមូលហេតុផ្នែកច្បាប់ និងអង្គហេតុ មុននឹងចេញដីកាសម្រេចបន្តការឃុំខ្លួន ហើយក៏មិនជាប់កាតព្វកិច្ចត្រូវបញ្ជាក់ពី កត្តានានាទាំងអស់នោះដែរ ។ ផ្ទុយពីអ្វីដែលមេធាវីការពារក្តីបានលើកឡើង ដីកាសម្រេចបន្តការឃុំខ្លួន មិនមានព័ត៌មានខុសណាមួយទេ ហើយការពិត ដើមបណ្តឹងឧទ្ធរណ៍ក៏បានទទួលនូវធាតុផ្សំទាំងអស់នៃសំណុំរឿង តាមរយៈមេធាវីការពារក្តីរបស់ខ្លួនហើយដែរ ។

(ខ) រយៈពេលនៃការឃុំខ្លួនបណ្តោះអាសន្ន មិនមែនមិនមានមូលហេតុនោះទេ ហើយក៏គ្មានកង្វះការយកចិត្តទុកដាក់ហ្មត់ចត់ ដោយស.ច.ស នៅក្នុងការអនុវត្តន៍កិច្ចដំណើរការនីតិវិធីដែរ ។ បទដ្ឋាននៃការយកចិត្តទុកដាក់ "ជាពិសេស" "គ្រប់គ្រាន់" ឬ "ដាច់ខាត" ដូច បានលើកឡើងដោយមេធាវីការពារក្តី មិនជាប់ពាក់ព័ន្ធគ្នាទេ នៅក្នុងកិច្ចដំណើរការនីតិវិធី នៅចំពោះមុខ អ.វ.ត.ក នោះ ដោយសារតែចរិតធម្មជាតិដ៏ជាក់លាក់ និងចម្រុះនៃការស៊ើបសួរ នៅក្នុងយុត្តាធិការរបស់ខ្លួន ដូចដែលបានជំទាស់ដោយតុលាការសិទ្ធិមនុស្សនៃទ្វីបអឺរ៉ុប ECHR។

(គ) ការធ្វើឲ្យខូចដល់សិទ្ធិនៅស្ងៀមមិនឆ្លើយតបរបស់ដើមបណ្តឹងឧទ្ធរណ៍ ដូចដែលបានលើកឡើង ហាក់ដូចជាបានផ្អែកទៅលើការអានដែលមានកំហុសឆ្គងមួយ នៅលើដីកាសម្រេចបន្តការឃុំខ្លួន ។ សិទ្ធិនៅស្ងៀមមិនឆ្លើយតប ត្រូវបានទទួលស្គាល់ និងមិនមានការជំទាស់ពី ស.ច.ស ទេ។ ទោះជាយ៉ាងណាក៏ដោយ អវត្តមាននៃកិច្ចសហការរបស់ដើមបណ្តឹងឧទ្ធរណ៍ មិនបានជួយដល់ ស.ច.ស នៅក្នុងការស្វែងរកភស្តុតាងដោះបន្ទុកឡើយ ។

(ឃ) ដើមបណ្តឹងឧទ្ធរណ៍ មិនបានបង្ហាញឲ្យឃើញអំពីការផ្លាស់ប្តូរកាលៈទេសៈជាក់ស្តែងណាមួយ តាំងពីគាត់ត្រូវបានចាប់ឃុំខ្លួនពីដំបូង ដោយ ស.ច.ស នៅថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ ២០០៧ មក ("ដីកាបង្គាប់ឲ្យឃុំខ្លួន")[2] ហើយគាត់ក៏មិនបានធ្វើដូច្នេះ ចាប់តាំងពីការឃុំខ្លួន

---

[2] *ករណីរបស់ អៀងធីរិទ្ធ*, ដីកាបង្គាប់ឲ្យឃុំខ្លួន, ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៧, C 21, ERN 00153250-52 (ភាសាអង់គ្លេស) [*ចាប់ពីនេះតទៅហៅថា* ដីកាបង្គាប់ឲ្យឃុំខ្លួន] ។

ត្រូវបានបញ្ជាក់អះអាងដោយ អ.ប.ជ នៅថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០០៨ នោះមក ("សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការឃុំខ្លួន")[3] ។ នៅក្នុង សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការឃុំខ្លួន ដែលបានវាយតម្លៃលើគ្រប់ភស្តុតាងទាំងអស់នៅលើសំណុំរឿងដែលធ្វើបច្ចុប្បន្នភាពចំពោះសវនាការនៃបណ្តឹងឧទ្ធរណ៍នេះ អ.ប.ជ បានកត់សំគាល់ថា លក្ខខណ្ឌតម្រូវតាមវិធាន៦៣.៣.ក. និងវិធាន៦៣.៣.ខ.១, វិធាន៦៣.៣.ខ.២, វិធាន៦៣.៣.ខ.៣, និង វិធាន៦៣.៣.ខ.៥ នៅតែបានបំពេញទៅតាម ហើយ "ការឃុំខ្លួនបណ្តោះអាសន្ន គឺនៅតែជាវិធានការចាំបាច់មួយ បើផ្អែកទៅលើទស្សនីករណ៍ [ទាំងនោះ]" ។

(ង) លក្ខខណ្ឌផ្សេងៗសម្រាប់ការឃុំខ្លួនតាមវិធាន៦៣.៣ គឺនៅតែបំពេញបាន រហូតមកដល់សព្វថ្ងៃនេះ៖ សំណុំរឿងមានភស្តុតាងដែលអាចបំពេញចំពោះអ្នកសង្កេតការណ៍ ឯករាជ្យនៅក្នុងដំណាក់កាលនៃកិច្ចស៊ើបសួរនេះ ដែលថា ដើមបណ្តឹងឧទ្ធរណ៍អាចត្រូវបានប្រព្រឹត្តបទឧក្រិដ្ឋនានា ដែលនៅពេលបច្ចុប្បន្ននេះ គាត់កំពុងតែស្ថិតនៅក្រោមកិច្ចស៊ើបសួរ (វិធាន៦៣.៣.ក) ។ ជាការបន្ថែម លក្ខខណ្ឌដាច់ដោយឡែកពីគ្នា ដូចមាននៅក្នុងវិធាន៦៣.៣.ខ គឺនៅតែត្រូវបានបំពេញ ព្រមទាំងបានជួយពង្រឹងថែមទៀត តាមរយៈឈុតនៃឧប្បត្តិហេតុផ្សេងៗដែលកើតមានជាបន្តបន្ទាប់។ ហេតុដូចនេះការឃុំខ្លួនបណ្តោះអាសន្ន គឺជាវិធានការចាំបាច់មួយ ។ ជាពិសេស ការឃុំខ្លួនបណ្តោះអាសន្នដើមបណ្តឹងឧទ្ធរណ៍ គឺជាការដ៏ចាំបាច់ដើម្បី (១) រារាំងកុំឲ្យជនត្រូវចោទ គាបសង្កត់ទៅលើសាក្សី ឬជនរងគ្រោះ និងដើម្បីថែរក្សាភស្តុតាង (២) ការពារមិនឲ្យបំផ្លាញភស្តុតាង (៣) ធានាអំពីវត្តមានរបស់ជនត្រូវចោទនៅក្នុងដំណើរការនីតិវិធី (៤) ការពារសន្តិសុខឲ្យជនត្រូវចោទ និង (៥) រក្សាសណ្តាប់ធ្នាប់សាធារណៈ ។

## ២. ប្រវត្តិនីតិវិធីពាក់ព័ន្ធ

[3] *ករណីរបស់ អៀង ធីរិទ្ធ,* សាលដីការបស់ អ.ប.ជ លើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នជនត្រូវចោទ អៀង ធីរិទ្ធ, ចុះថ្ងៃទី៩ ខែកក្កដា ឆ្នាំ២០០៨, C 20/I/26, ERN 00201588-604 (ជាភាសាអង់គ្លេស) ។ [*ចាប់ពីនេះតទៅហៅថា* សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការឃុំខ្លួនរបស់ អៀង ធីរិទ្ធ] ។

៣. នៅថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៧ សហព្រះរាជអាជ្ញា បានដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរមួយ ដែលលំអិតអំពីអង្គហេតុនានា ព្រមទាំងបង្ហាញឈ្មោះដើមបណ្តឹងឧទ្ធរណ៍ និងជនសង្ស័យបួននាក់ផ្សេងទៀត ថាជាអ្នកទទួលខុសត្រូវចំពោះបទឧក្រិដ្ឋជាក់លាក់ ដែលស្ថិតនៅក្នុងយុត្តាធិការរបស់តុលាការនេះ ដូចដែលបានពិពណ៌នានៅក្នុងដីកានោះ ។ ដើមបណ្តឹង-ឧទ្ធរណ៍រូបនេះ ត្រូវបានចាប់ខ្លួននៅថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០០៧[4] នៅចំពោះមុខ ស.ច.ស ដើម្បីចូលបង្ហាញខ្លួនលើកដំបូង[5] នៅថ្ងៃដដែលនោះ និងត្រូវបានចោទប្រកាន់ចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលបានប្រព្រឹត្ត ចាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ ។ សវនាការដេញដោលមួយស្តីពីការឃុំខ្លួន ត្រូវបានធ្វើឡើងនៅថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៧[6] បន្ទាប់មកទៀត ស.ច.ស បានចេញដីកាបង្គាប់ឱ្យឃុំខ្លួនបណ្តោះអាសន្ន អៀង ធីរិទ្ធ សម្រាប់រយៈពេលមួយឆ្នាំ[7] និងបានចេញដីកាបង្គាប់ឱ្យឃុំខ្លួន[8] ។ តាំងពីពេលមានសវនាការដេញដោលមក ដើមបណ្តឹងឧទ្ធរណ៍បានប្រើប្រាស់ សិទ្ធិនៅស្ងៀមមិនឆ្លើយតបរបស់ខ្លួន[9] ។ នៅថ្ងៃទី២ ខែមករា ឆ្នាំ២០០៨ ដើមបណ្តឹងឧទ្ធរណ៍ បានដាក់បណ្តឹងឧទ្ធរណ៍មួយប្រឆាំងនឹងដីកាបង្គាប់ឱ្យឃុំខ្លួន[10] ដែលសហព្រះរាជអាជ្ញាបានឆ្លើយតប នៅថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៨[11] ។ សវនាការជាសាធារណៈស្តីពីការឃុំខ្លួនបណ្តោះអាសន្ន ដែលពីដំបូង

---

[4] *ករណីរបស់ អៀង ធីរិទ្ធ,* របាយការណ៍ស្តីពីការនាំខ្លួន អៀង សារី និង អៀង ធីរិទ្ធ និងការឆែកឆេរលំនៅដ្ឋាននៅទីក្រុងភ្នំពេញ ចុះថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០០៧, D 31/III, ERN 00153309-10 ។ សូមអានផងដែរ កំណត់ហេតុនៃការឆែកឆេរលំនៅដ្ឋានរបស់ អៀង សារី និង អៀង ធីរិទ្ធ, ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០០៧, D 31/I, ERN 00152226-29 និង ERN 00157577-78; កំណត់ហេតុនៃការទទួលវត្ថុតាង ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០០៧, D 31/II, ERN 00152224-25 និង ERN 00157576 ។

[5] *ករណីរបស់ អៀង ធីរិទ្ធ,* កំណត់ហេតុនៃចូលខ្លួនដំបូង លេខស៊ើបសួរ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក-ក.ស.ច.ស, ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០០៧, D 39, ERN 00153315-17 (ភាសាអង់គ្លេស), 00152284-88 (ភាសាខ្មែរ), 00153329-32 (ភាសាបារាំង) ។

[6] *ករណីរបស់ អៀង ធីរិទ្ធ,* កំណត់ហេតុនៃកិច្ចពិភាក្សាដេញដោល, ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៧, C 18, ERN 00153383-88 ។

[7] *ករណីរបស់ អៀង ធីរិទ្ធ,* ដីកាបង្គាប់ឱ្យឃុំខ្លួនបណ្តោះអាសន្ន, ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៧, C 20, ERN 00153245-49 ។

[8] *ករណីរបស់ អៀង ធីរិទ្ធ,* ដីកាបង្គាប់ឱ្យឃុំខ្លួន, ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៧, C 21, ERN 00153250-52 ។

[9] (បានលុបចេញ)

[10] *ករណីរបស់ អៀង ធីរិទ្ធ,* បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបង្គាប់ឱ្យឃុំខ្លួនបណ្តោះអាសន្ន, ចុះថ្ងៃទី២ ខែមករា ឆ្នាំ២០០៨, C20/I/3, ERN 00157111-00157280 (ភាសាអង់គ្លេស) ។

[11] *ករណីរបស់ អៀង ធីរិទ្ធ,* ចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ ដែលជំទាស់នឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០០៨, C 20/I/7, ERN 00186408-34 (ភាសាអង់គ្លេស) ។

ត្រូវបានកំណត់យកថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៨ ត្រូវបានលើកពេលតាមសំណើរបស់មេធាវីការពារក្ដី[12] មកថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៨ វិញ[13]។ នៅមុនពេលសវនាការនេះ គឺនៅថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០០៨ សហព្រះរាជអាជ្ញាបានស្នើទៅ ស.ច.ស ឱ្យទទួលយក (បានលុបចេញ) ទុកជាការពាក់ព័ន្ធនៅក្នុងការបង្ហាញភស្ដុតាងអំពីតួនាទីរបស់ អៀង ធីរិទ្ធ នៅក្នុងឧក្រិដ្ឋកម្ម ដូចបានចោទឡើងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ[14] ។ ថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០០៨ ចៅក្រម អ.ប.ជ បានចេញ "សាលដីកាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្នជនត្រូវចោទ អៀង ធីរិទ្ធ"[15]។ នៅថ្ងៃទី១៣ ខែតុលា ឆ្នាំ២០០៨ អនុលោមតាមវិធាន៦៣.៧ ស.ច.ស បានជូនដំណឹងដល់ជនត្រូវចោទ និងមេធាវីការពារក្ដីរបស់គាត់ថា ស.ច.ស បាននិងកំពុងពិចារណាអំពីការបន្ដថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្នរបស់គាត់ និងបានស្នើឱ្យពួកគេដាក់សេចក្ដីសង្កេតរបស់ខ្លួន នៅក្នុងរយៈពេលកំណត់ ១៥ថ្ងៃ[16] ហើយពួកគេក៏បានធ្វើដូច្នោះមែន នៅថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៨[17] ។ នៅថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០០៨ ស.ច.ស បានចេញដីកាសម្រេចអំពីកាបន្តថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្នរបស់ខ្លួនលើជនត្រូវចោទ អៀង ធីរិទ្ធ ដែលបានជូនដំណឹងនៅថ្ងៃទី១១

---

[12] *ករណីរបស់ អៀង ធីរិទ្ធ*, សំណើសុំពន្យារពេលសវនាការលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាឃុំខ្លួនបណ្ដោះអាសន្ន ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០០៨, C 20/I/9, ERN 00172273-76 (ភាសាអង់គ្លេស) ។ សេចក្ដីសម្រេចកែប្រែកាលបរិច្ឆេទសវនាការ - ផ្លាស់ប្ដូរពេលវេលាអនុវត្ត, ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០០៨, C 20/I/18, ERN 00181516-17 (ភាសាអង់គ្លេស) ។

[13] *ករណីរបស់ អៀង ធីរិទ្ធ*, ប្រតិចារឹកនៃសវនាការ អ.ប.ជ ស្ដីពីការឃុំខ្លួនបណ្ដោះអាសន្ន ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៨, ERN 00220079-164 (ភាសាអង់គ្លេស), ERN 00220246-326 (ភាសាខ្មែរ), ERN 00220165-245 (ភាសាបារាំង) ។

[14] *ករណីរបស់ អៀង ធីរិទ្ធ*, សំណើរបស់សហព្រះរាជអាជ្ញា សុំឱ្យដាក់បញ្ចូលនូវចម្លើយមួយ ដើម្បីបង្ហាញភស្ដុតាងអំពីតួនាទីរបស់ អៀង ធីរិទ្ធ នៅក្នុងឧក្រិដ្ឋកម្មទាំងឡាយដែលបានចោទប្រកាន់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០០៨, D 85, ERN 00191111-18 (ភាសាអង់គ្លេស) ។ ស.ច.ស បានអនុញ្ញាតតាមសំណើ និងបានចេញដីកាបង្គាប់មួយឱ្យលុបចេញផ្នែកខ្លះនៃអាសយដ្ឋានរបស់សាក្សី តាមសំណើរបស់ ក.ស.ព (D85/1) ។ យោងតាមសំណើសុំវិធានការការពារ សំណើនេះមិនត្រូវបានគេជូនដំណឹងទាន់ពេលវេលាដល់ភាគី ដើម្បីជជែកពិភាក្សានៅពេលសវនាការនៅថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៨ នោះទេ ។

[15] សាលដីកាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងការឃុំខ្លួនរបស់ អៀង ធីរិទុត, C 20/I/26, ERN 00201588-604 (ជាភាសាអង់គ្លេស) ។

[16] *ករណីរបស់ អៀង ធីរិទ្ធ*, សេចក្ដីជូនដំណឹងរបស់ ស.ច.ស ស្របតាមវិធាន៦៣.៧ នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០០៨, C 20/2, ERN 00231614-15 (ភាសាអង់គ្លេស) ។

[17] *ករណីរបស់ អៀង ធីរិទ្ធ*, ការជំទាស់តវ៉ារបស់មេធាវីការពារក្ដី ទៅនឹងគោលបំណងរបស់សហចៅក្រមស៊ើបអង្កេត នៅក្នុងការបន្តឃុំខ្លួនបណ្ដោះអាសន្នអ្នកស្រី អៀង ធីរិទ្ធ, ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៨, C 20/3, ERN 00235246-257 (ភាសាអង់គ្លេស) ។

ខែវិច្ឆិកា ឆ្នាំ២០០៨[18] ។ នៅថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០០៨ មេធាវីការពារក្តីបានដាក់សេចក្តីជូនដំណឹងមួយ អំពីបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចអំពីកាបន្តថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នលើជនត្រូវចោទ អៀង ធីរិទ្ធ ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០០៨[19] នៅមុនពេលដាក់បណ្តឹងឧទ្ធរណ៍ជាសារវន្តរបស់ខ្លួន នៅថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០០៨[20] ។

## ៣. សេចក្តីសន្និដ្ឋានបឋម

### *សវនាការផ្ទាល់មាត់មិនចាំបាច់ទេ*

៤. វិធាន៧៧.៣ នៃវិធានផ្ទៃក្នុង ("វិធាន") អនុញ្ញាតឲ្យអង្គបុរេជំនុំជម្រះ កំណត់សម្រេចលើបណ្តឹងឧទ្ធរណ៍ណាមួយ តែនៅលើមូលដ្ឋាននៃសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរប៉ុណ្ណោះ បន្ទាប់ពីបានធ្វើការពិចារណានៅលើទស្សនៈផ្សេងៗរបស់ភាគី ។ ដើមបណ្តឹងឧទ្ធរណ៍មិនបានសុំឲ្យមានសវនាការផ្ទាល់មាត់ណាមួយទេ ចំពោះបណ្តឹងឧទ្ធរណ៍នេះ ។ ដូចដែលសវនាការធ្វើការកំណត់សម្រេចលើការឃុំខ្លួននឹងត្រូវធ្វើដោយផ្ទាល់មាត់ បណ្តឹងឧទ្ធរណ៍នេះមានកង្វល់តែអំពីការបន្តថិរវេលានៃការឃុំខ្លួនដែលបានបញ្ជាក់អះអាងរួចហើយតែប៉ុណ្ណោះ ដូច្នេះវាមិនមានអំណះអំណាងទាំងផ្នែកអង្គហេតុ និងអង្គច្បាប់ថ្មីដែលចាំបាច់ត្រូវលើកយកមកពិចារណានៅក្នុងសវនាការផ្ទាល់មួយនោះឡើយ ។ អាស្រ័យហេតុនេះ ដើម្បីជាប្រយោជន៍ផ្នែកសេដ្ឋកិច្ចរបស់តុលាការ សហព្រះរាជអាជ្ញាសូមស្នើឲ្យអង្គបុរេជំនុំជម្រះកំណត់សម្រេចនៅលើបណ្តឹងនេះ ដោយធ្វើសេចក្តីសន្និដ្ឋានជាលាយលក្ខអក្សរតែប៉ុណ្ណោះ ។

---

[18] *ករណីរបស់ អៀង ធីរិទ្ធ,* ដីកាសម្រេចអំពីកាបន្តថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នរបស់ស.ច.ស ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០០៨, C 20/4, ERN 00238528-46 (ភាសាអង់គ្លេស) [*ចាប់ពីនេះតទៅហៅថា* "ដីកាសម្រេចបន្តការឃុំខ្លួន"] ។

[19] *ករណីរបស់ អៀង ធីរិទ្ធ,* សៀវភៅចុះបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០០៨, C20/5, ERN 2329730-31 (ភាសាអង់-គ្លេស); សេចក្តីជូនដំណឹងពីបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់ស.ច.ស អំពីកាបន្តថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន អៀង ធីរិទ្ធ ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០០៨ ដែលសេចក្តីជូនដំណឹងនេះ ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០០៨, C 20/5, ERN 00239732-33 (ភាសាអង់គ្លេស) ។

[20] *ករណីរបស់ អៀង ធីរិទ្ធ,* បណ្តឹងឧទ្ធរណ៍របស់មេធាវីការពារក្តីអៀង ធីរិទ្ធ ប្រឆាំងនឹង "ដីកាសម្រេចអំពីការបន្តថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន" ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០០៨, ចុះកាលបរិច្ឆេទថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០០៨, C 20/5/1, ERN 00250142-63 (ភាសាអង់គ្លេស) [*ចាប់ពីនេះតទៅហៅថា* "បណ្តឹងឧទ្ធរណ៍"] ។

## ៤. អង្គច្បាប់

### *ចរិត និង វិសាលភាពនៃការត្រួតពិនិត្យរបស់ អ.ប.ជ*

៥. អំណះអំណាងរបស់មេធាវីការពារក្ដី នៅក្នុងកថាខណ្ឌទី១៣ ដល់ កថាខ័ណ្ឌទី៥៦ នៃបណ្ដឹង-ឧទ្ធរណ៍ មិនមានការពាក់ព័ន្ធជាសារវ័ន្តចំពោះបញ្ហានៃការបន្តការឃុំខ្លួនបណ្ដោះអាសន្នទេ ។ មេធាវីការពារក្ដីតវ៉ាថា ដីកាសម្រេចបន្តការឃុំខ្លួន គឺមានការខ្វះចន្លោះ ហេតុដូច្នេះ ត្រូវតែច្រានចោល ។ មេធាវីការពារក្ដីមិនបានយកចិត្តទុកដាក់ទៅលើអង្គហេតុដែលថា បញ្ហាជាចំបងនៅក្នុងការកំណត់សម្រេចលើបណ្ដឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាសម្រេចបន្តថិរ វេលានៃការឃុំខ្លួននេះ ថាតើលក្ខខណ្ឌនានាដូចបានកំណត់នៅក្នុងវិធាន៦៣.៣ នៅតែត្រូវបាន បំពេញឬយ៉ាងណានោះទេ ។ មេធាវីការពារក្ដីហាក់ដូចជាបានយល់ច្រឡំអំពីចរិត និងវិសាល ភាពនៃការត្រួតពិនិត្យរបស់ អ.ប.ជ នៅពេលដែលខ្លួនបានដាក់បណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់ ស.ច.ស ។ នៅអ.វ.ត.ក អង្គបុរេជំនុំជម្រះ មិនមែនជាតុលាការនៃ “សាលាវិនិច្ឆ័យ” ទេ ។ អ.ប.ជ មិនចាំបាច់ត្រូវពិនិត្យសំណុំរឿង និងលក្ខខណ្ឌនានានៃវិធាន៦៣.៣ នៅពេល ដែល ស.ច.ស បានចេញដីកាសម្រេចបន្តថិរវេលានៃការឃុំខ្លួនរបស់គេនោះទេ[21] ។ ដូចបានរំលឹកដោយ អ.ប.ជ នៅក្នុងសេចក្ដីសម្រេចប្រកបដោយជោគជ័យរបស់ខ្លួនលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបង្គាប់ឲ្យឃុំខ្លួនបណ្ដោះអាសន្ន អ.ប.ជ ពិចារណាទៅលើសំណុំរឿងទាំង មូលរបស់ ស.ច.ស រហូតមកទល់នឹងថ្ងៃបើកសវនាការ[22] រួមទាំងធាតុផ្សំ

---

[21] ការពិនិត្យឡើងវិញលើដីកាបង្គាប់ឲ្យឃុំខ្លួនបណ្ដោះអាសន្នរបស់ អ.ប.ជ “ដោយការពិនិត្យទៅលើ៖ ក. នីតិវិធីរបស់សហចៅក្រមស៊ើបអង្កេត មុនពេលចេញដីកានេះ, ខ. ភាពគ្រប់គ្រាន់នៃអង្គហេតុ ក្នុងការចេញដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្ន ស្របតាមវិធាន ៦៣.៣ នៃវិធានផ្ទៃក្នុង, គ. ថាតើកាលៈទេសៈដែលដីកាបានយកមកធ្វើជាសំអាង នៅមានអត្ថិភាពនាពេលបច្ចុប្បន្ន ដែរឬទេ និង ឃ. ការអនុវត្តន៍ឆន្ទានុសិទ្ធិរបស់សហចៅក្រមស៊ើបអង្កេត ដោយគោរពតាមវិធាន៦៣.៣ នៃវិធានផ្ទៃក្នុង” *នៅក្នុង* សាលដីកាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងការឃុំខ្លួនរបស់ អៀង ធីរិទ្ធ, C 20/I/26, ERN 00201588-604 (ភាសាអង់គ្លេស), ត្រង់ ERN 00201591, កថាខណ្ឌទី១៥ ។ សាលដីកាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្នជនត្រូវចោទ នួន ជា, ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០០៨, C 11/54, ERN 00172907-34 (ភាសាអង់គ្លេស), នៅត្រង់ ERN 00172909 កថាខណ្ឌទី ៩ ។

[22] ឧទាហរណ៍ សាលដីកាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងការឃុំខ្លួនរបស់ អៀង ធីរិទ្ធ, C 20/I/26, ERN 00201588-604 (ភាសាអង់គ្លេស), ត្រង់ ERN 00201592, កថាខណ្ឌទី២០ ។

ថ្មីៗ និងចំណែកនៃ ភស្តុតាងណាក៏ដោយ ដែលបានដាក់តាំងពីមានបណ្តឹងឧទ្ធរណ៍មក ។ អាស្រ័យហេតុនេះ អ.ប.ជ អាចដាក់សេចក្តីសម្រេច សំអាងហេតុ និងមូលហេតុរបស់ខ្លួនផ្ទាល់ ជំនួសឲ្យសេចក្តីសម្រេច សំអាងហេតុ និងមូលហេតុដែលមាននៅក្នុងដីកាសម្រេចរបស់ ស.ច.ស[23] ។ ក្នុង ករណីវិការៈ អ.ប.ជ នៅតែអាច "ធ្វើការវិភាគផ្ទាល់ខ្លួន ដោយអនុវត្តតាមបទដ្ឋានដែលមាន ចែងនៅក្នុងវិធាន៦៣.៣"[24] និងបំពេញវិការៈនោះ តាមរយៈការដាក់ជំនួសនូវសំអាងហេតុរបស់ខ្លួនផ្ទាល់[25] ។

## *ភាពកិច្ចក្នុងការផ្តល់សំអាងហេតុនៅក្នុងដីកាសម្រេចបន្តថិរវេលានៃការឃុំខ្លួន*

៦. មេធាវីការពារក្តីតវ៉ាថា ដីកាសម្រេចបន្តថិរវេលានៃការឃុំខ្លួន មិនមានសំអាងហេតុគ្រប់គ្រាន់ ឬសមល្មមទេ ដោយសារ (ក) គ្មានប្រភពសម្រាប់ការចោទប្រកាន់, (ខ) ដីកាសម្រេចបន្តថិរវេលានៃការឃុំខ្លួន មានផ្ទុកនូវព័ត៌មានមិនត្រឹមត្រូវ និង (គ) ដើមបណ្តឹងឧទ្ធរណ៍ មិនទទួលបានលទ្ធភាពពេញលេញចូលមើលសំណុំរឿង ។

៧. វិធាន៦៣.៧ តម្រូវឲ្យសហចៅក្រមស៊ើបអង្កេត "ត្រូវមានសំអាងហេតុ" ចំពោះការពន្យារពេលនៃការបន្តការឃុំខ្លួន ។ សំអាងហេតុទាំងអស់នេះត្រូវតែផ្តល់ បន្ទាប់ពីបានពិចារណាទៅ

---

[23] អ.ប.ជ ជាធម្មតាបញ្ជាក់ថា *"តម្កល់ដីការបស់សហចៅក្រមស៊ើបអង្កេត ហើយមូលហេតុដែលបានបញ្ជាក់ក្នុងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នរបស់សហចៅក្រមស៊ើបអង្កេត ត្រូវបានជំនួសដោយមូលហេតុដែលបានបញ្ជាក់ក្នុងសាលដីកានេះ"* ។ ឧទាហរណ៍ សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការឃុំខ្លួនរបស់ អៀង ធីរិទ្ធ, C 20/I/26, ERN 00201588-604 (ភាសាអង់គ្លេស), ត្រង់ ERN 00201605 (ត្រង់សេចក្តីសម្រេច, កថាខណ្ឌទីចុងក្រោយ) ។

[24] សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការឃុំខ្លួនរបស់ អៀង ធីរិទ្ធ, C 20/I/26, ERN 00201588-604 (ភាសាអង់គ្លេស), ត្រង់ ERN 00201592, កថាខណ្ឌទី១៨ ។

[25] អ.ប.ជ បានបញ្ជាក់នៅក្នុងកថាខ័ណ្ឌទី៤២ នៃសាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការឃុំខ្លួនរបស់ អៀង ធីរិទ្ធ, (C 20/I/26, ត្រង់ ERN 00201598) ថា *"អង្គបុរេជំនុំជម្រះបានសង្កេតឃើញថា ការព្រួយបារម្ភជាច្រើន ដែលសហមេធាវីការពារក្តីបានលើកឡើងអំពីករណីដែលសហចៅក្រមស៊ើបអង្កេត មិនគោរពគោលការណ៍នៃសច្ចធារនិរទោស ត្រូវដោះស្រាយ តាមរយៈការវិភាគដែលអង្គបុរេជំនុំជម្រះនេះ បានអនុវត្ត"* ។

លើសំណុំរឿង និងការតវ៉ារបស់ជនជាប់ឃុំឃាំង[26] ។ ដោយបានលើកយោងនូវករណីយុត្តិ-សាស្ត្រអន្តរជាតិដែលគេបានឯកភាពគ្នាហើយនោះ អ.ប.ជ បានរកឃើញថា សេចក្តីសម្រេចទាំងអស់របស់អង្គតុលាការ រួមទាំង ស.ច.ស ផង ត្រូវតែមានសំអាងហេតុ ដើម្បីបំពេញបាននូវបទដ្ឋានអន្តរជាតិ[27] ។

៨. អ.ប.ជ បានកំណត់ថា កាតព្វកិច្ចក្នុងការផ្តល់សំអាងហេតុ បានដាក់លក្ខខណ្ឌតម្រូវត្រឹមតែថា ស.ច.ស ត្រូវកំណត់មូលហេតុខាងផ្លូវច្បាប់ និងអង្គហេតុដែលត្រូវយកមកគិតគូរ មុននឹងធ្វើការសម្រេច ។ ស.ច.ស អាចអនុវត្តកាតព្វកិច្ចនេះ "ដោយយោងលើសំណុំរឿងក្នុងកាលៈទេសៈទូទៅ និងកាលៈទេសៈដទៃទៀត" ដោយសារ ស.ច.ស មិនមានកាតព្វកិច្ចផ្តល់ការយល់ឃើញរបស់ខ្លួនលើគ្រប់កត្តាទាំងអស់ឡើយ[28] ។ ហេតុដូច្នេះ សារណារបស់មេធាវីការពារក្តីដែលថា "ដីកាសម្រេចបន្តការឃុំខ្លួន មានការខ្វះខាតលើមូលហេតុ ដែលធ្វើការចោទប្រកាន់ទូទៅ ដោយគ្មានផ្តល់ប្រភពសម្រាប់ការចោទប្រកាន់"[29] នោះ គឺរកមិនឃើញទេ និងគួរតែត្រូវបានបដិសេធចោល ។

---

[26] អនុលោមតាមវិធាន៦៣.៧ នៃវិធានផ្ទៃក្នុង នីតិវិធីបន្តការឃុំខ្លួន កើតឡើងតែរវាង ស.ច.ស និងជនត្រូវចោទតែប៉ុណ្ណោះ ដោយសារនៅពេលមានការពន្យារពេលនៃការឃុំខ្លួនបណ្តោះអាសន្នណាមួយ ស.ច.ស ស្តាប់ការប្តឹងតវ៉ារបស់ជនត្រូវចោទ ។ គ្មានភាគីណាផ្សេងត្រូវបានធ្វើសវនាការ ឬ ត្រូវពាក់ព័ន្ធនៅក្នុងដំណើរការនេះទេ ។ អាស្រ័យហេតុនេះហើយ ដំណើរការនៃការបន្តការឃុំខ្លួន តាមវិធាន ៦៣.៧ នេះ មានភាពខុសគ្នាគួរឱ្យកត់សំគាល់ពីដំណើរការនៃការឃុំខ្លួនដំបូង តាមវិធានវិធាន៦៣.៣ ដែលរួមបញ្ចូលទាំងសវនាការដេញដោលនៅចំពោះមុខ ស.ច.ស ផង ។

[27] *ករណីរបស់ នួន ជា*, សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ នួន ជា ប្រឆាំងចំពោះដីកាបដិសេធពាក្យសុំមោឃភាព, សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ០៦) ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០០៨, D 55/I/8, ERN 001219322-33 (ភាសាអង់គ្លេស), កថាខណ្ឌទី២១ ។

[28] *ករណីរបស់ អៀង សារី*, សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នជនត្រូវចោទ អៀង សារី, សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ០៣) ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ២០០៨, ERN 00232976-004, C 22/I/74, កថាខណ្ឌទី៦៥-៦៦ ។ *សូមអានផងដែរ* ករណីយុត្តិសាស្ត្រ ICTY: *រដ្ឋអាជ្ញា ទល់នឹង Popovic*, ដីកាសម្រេចលើបណ្តឹងឧទ្ធរណ៍បន្ទាន់បង្ខំរបស់មេធាវីការពារក្តីដែលប្តឹងអំពីសេចក្តីសម្រេចរបស់អង្គជំនុំជម្រះបដិសេធលើការដោះលែងបណ្តោះអាសន្ន Ljubomir Borovcanin, ករណីរឿងក្តីលេខ: IT-05-88-AR65.2, អង្គជំនុំជម្រះសាលាឧទ្ធរណ៍ ចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០០៧, កថាខណ្ឌទី១៣ ។ *រដ្ឋអាជ្ញា ទល់នឹង Haradinaj* សេចក្តីសំរេចលើញត្តិតវ៉ាសុំឱ្យដោះលែងជាបណ្តោះអាសន្នរបស់ Lahi Brahimaj, សំណុំរឿងលេខ: IT-04-84-PT, អង្គជំនុំជម្រះសាលាដំបូងរបស់ ICTY, ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០០៦ កថាខណ្ឌទី១៦ ។

[29] បណ្តឹងឧទ្ធរណ៍, C 20/5/1, កថាខណ្ឌទី១៦ ។

៩. មេធាវីការពារក្ដីតវ៉ាបន្ថែមទៀតថា ដីកាសម្រេចបន្តថិរវេលានៃការឃុំខ្លួនមានផ្ទុកនូវព័ត៌មានមិនត្រឹមត្រូវ[30] ។ ការអះអាងនេះ មិនត្រឹមត្រូវទេ ដូចឯកសារទាំងពីរបានយោងសំដៅនៅក្នុងកំណត់សំគាល់ចុងទំព័រទី១៤ នៃដីកាសម្រេចបន្តការឃុំខ្លួន (D88 និង 85/1) ដែលមានការព្រួយបារម្ភដោយផ្ទាល់ទៅលើចំណេះដឹងរបស់ អៀង ធីរិទ្ធ និងតួនាទីរបស់គាត់ក្នុងសកម្មភាពបោសសម្អាត ឬតួនាទីរបស់ក្រសួងសង្គមកិច្ច (បានលុបចេញ)[31] ។

១០. នៅទីបំផុត មេធាវីការពារក្ដី បានលើកឡើងផ្ទុយពីសេចក្ដីសម្រេចរបស់ ស.ច.ស នៅក្នុងដីកាសម្រេចពន្យារពេល គឺថាដើមបណ្ដឹងឧទ្ធរណ៍នឹងមិនមានមធ្យោបាយក្នុងការទទួលបាននូវសំណុំរឿងទេ ។ ហេតុដូច្នេះ ដីកាសម្រេចពន្យារពេល បំពានទៅលើលក្ខខណ្ឌតម្រូវដែលថាសេចក្ដីសម្រេចរបស់តុលាការត្រូវតែមានមូលហេតុសមស្រប[32] ។

១១. ទីមួយ វិធានផ្ទៃក្នុងដែលអនុវត្តនៅ អ.វ.ត.ក មិនមានចែងថា ជនត្រូវចោទ ឬដើមបណ្ដឹងរដ្ឋប្បវេណី អាចទទួលបាននូវសំណុំរឿងដោយចំពោះ និងដោយផ្ទាល់ឡើយ[33] ។ ទោះជាយ៉ាង

---

[30] បណ្ដឹងឧទ្ធរណ៍, C 20/5/1, កថាខណ្ឌទី១៨-២០ ។

[31] (បានលុបចេញ)

[32] បណ្ដឹងឧទ្ធរណ៍, C20/5/1, កថាខណ្ឌទី ២១-២៤ ។

[33] ផ្ទុយពីអ្វីដែលមេធាវីបានស្នើនៅក្នុងសំណើសុំការបំភ្លឺរបស់ខ្លួន ចុះថ្ងៃទី២១ តុលា ២០០៨ (A 228), មាត្រា ១៥៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មិនអាចអនុវត្តបានទៅនឹងនីតិវិធីសម្រាប់ អ.វ.ត.ក ដោយសារវាផ្ទុយនឹងវិធាន ២២.៣ នៃវិធានផ្ទៃក្នុង ។ ដូចដែល អបជ បានសម្រេចថ្មីៗនេះវិធានផ្ទៃក្នុងមានអានុភាពលើបទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា៖ នៅថ្ងៃទី២៦ សីហា ២០០៨ អបជ បានសម្រេចនៅក្នុងកថាខណ្ឌទី ១៤ នៃសាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ នួន ជា ប្រឆាំងចំពោះដីកាបដិសេធពាក្យសុំមោឃភាពថា វិធានផ្ទៃក្នុងជាលិខិតុបករណ៍បឋម ដែលគេត្រូវប្រើសម្រាប់យោងសេចក្ដីក្នុងការកំណត់អំពីដំណើរការនីតិវិធីនៅចំពោះមុខ អ.វ.ត.ក កាលបើមានការខុសគ្នារវាងដំណើរការនីតិវិធីក្នុងវិធានផ្ទៃក្នុង និងក្នុងក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា (*ករណីរបស់ នួន ជា*, សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ នួន ជា ប្រឆាំងចំពោះដីកាបដិសេធពាក្យសុំមោឃភាព, ចុះថ្ងៃទី២៦ សីហា ២០០៨, **D 55/1/8**, ERN 0012193 34-49 (ភាសាខ្មែរ) និង 001219322-33 (ភាសាអង់គ្លេស), កថាខណ្ឌទី ១៤) ។ អបជ បានបញ្ជាក់គោលការណ៍នេះនៅក្នុងសេចក្ដីសម្រេចរបស់ខ្លួនលើសំណើរបស់សហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីទាក់ទងនឹងការធ្វើសេចក្ដីសន្និដ្ឋានដោយផ្ទាល់មាត់នៅពេលសវនាការចុះថ្ងៃទី០៤ធ្នូ២០០៨ (*ករណីរបស់ ខៀវ សំផន*, សេចក្ដីសម្រេចជាលាយល័ក្ខណ៍អក្សររបស់ អបជ ទៅលើសំណើដោយផ្ទាល់មាត់របស់សហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីទាក់ទងនឹងការធ្វើសេចក្ដីសន្និដ្ឋានដោយផ្ទាល់មាត់, ចុះថ្ងៃទី០៤ ធ្នូ ២០០៨, **A 190/I/16**, ERN 00244305-07 (ភាសាអង់គ្លេស), កថាខណ្ឌទី ២) ។

នេះក្តី វិធានចែងថា ភាគីនានាត្រូវទទួលបាននូវឯកសារគ្រប់យ៉ាងពីក្នុងសំណុំរឿង ដោយផ្ទាល់ (សហព្រះរាជអាជ្ញា) និងតាមរយៈមេធាវីការពារក្តីរបស់ពួកគេ (ជនត្រូវចោទ និងដើមបណ្តឹងរដ្ឋប្បវេណី)[34] ។ ទីពីរ នៅក្នុងសំណើសុំសេចក្តីបញ្ជាក់របស់មេធាវីការពារក្តីរបស់ពួកគេ ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០០៨[35] មេធាវីការពារក្តីមិនបានពិចារណាអំពីវិធាន ២២.៣ ដែលចែងយ៉ាងជាក់លាក់ថា មេធាវីការពារក្តីដែលបានទទួលស្គាល់អាចទទួលបានច្បាប់ចម្លងនៃសំណុំរឿង ឬកំណត់ហេតុនៃកិច្ចដំណើរការនីតិវិធី និងយកឯកសារនេះ រួមជាមួយឯកសារដែលពាក់ព័ន្ធដទៃទៀត ដើម្បីពិភាក្សាជាមួយកូនក្តីរបស់ខ្លួន[36] ។ លើកលែងតែសហមេធាវីការពារក្តីរបស់គាត់មិនទៅសួរសុខទុក្ខកូនក្តីរបស់ខ្លួន ឬមិនពិភាក្សាអំពីភស្តុតាងនៅក្នុងសំណុំរឿងជាមួយនឹងគាត់ នោះវាច្បាស់ណាស់ថា ដើមបណ្តឹងឧទ្ធរណ៍អាចទទួលតាមរយៈមេធាវីការពារក្តីរបស់ខ្លួនបានយ៉ាងមានប្រសិទ្ធភាពនូវ "ឯកសារគ្រប់យ៉ាងពីក្នុងសំណុំរឿង រួមទាំងកំណត់ហេតុស្តាប់ចម្លើយសាក្សីជាក់លាក់ ក៏ដូចជាបណ្តឹង និងការដាក់ពាក្យនានារបស់ដើមបណ្តឹងរដ្ឋប្បវេណីដែរ"ដូចដែល ស.ច.ស បានរំលឹកក្នុងដីកាសម្រេចបន្តការឃុំខ្លួន[37] ។ ក្រៅពីនេះ មេធាវីការពារក្តីទទួលស្គាល់នៅក្នុងបណ្តឹងឧទ្ធរណ៍របស់ខ្លួនថា ឯកសារជាក់លាក់មួយចំនួន នៅក្នុងសំណុំរឿងធ្លាប់ត្រូវបានផ្តល់ឲ្យទៅដើមបណ្តឹងឧទ្ធរណ៍[38] ។ ដូច្នេះ វាមិនត្រឹមត្រូវទេដែលមេធាវីការពារក្តីអះអាងអំពីអត្ថិភាពដែលបានចោទថា មានកង្វះខាតក្នុងការទទួលបាននូវសំណុំរឿង ហើយរឹតតែមិនត្រឹមត្រូវណាស់ទៅទៀតដែលថា ដីកាសម្រេចបន្ត

---

[34] វិធាន ៩.៥, ២២.៣, ៥៥.៦, ៥៥.១១, ៥៨.១, ៥៨.២, ៧៦.៦ និង ៧៧.៤ អនុញ្ញាតឲ្យភាគីនានាពិនិត្យមើល និងថតចម្លងសំណុំរឿងក្នុងដំណាក់កាលស៊ើបសួរ ហើយសហមេធាវីការពារក្តីយកវាទៅឲ្យជនជាប់ឃុំបាន ។ ក្នុងដំណាក់កាលសវនាការ ក៏មានបទប្បញ្ញត្តិស្រដៀងគ្នានេះដែរ ឧទាហរណ៍ វិធាន ៨៦ និង វិធាន ១០៨.៦ ។

[35] *ករណីរបស់ អៀង ធីរិទ្ធ,* សំណើរបស់មេធាវីសុំសេចក្តីបំភ្លឺលើការអនុវត្តន៍វិធានទាក់ទងនឹងជនត្រូវចោទទទួលឯកសារនៅក្នុងសំណុំរឿង, ចុះថ្ងៃទី២១ តុលា ២០០៨, A 228 ។

[36] លើសពីនេះ វិធាន ៩.២១ នៃវិធានស្តីពីការគ្រប់គ្រងការឃុំខ្លួនជនដែលរង់ចាំការជំនុំជម្រះ ឬប្តឹងឧទ្ធរណ៍នៅចំពោះមុខ អ.វ.ត.ក "វិធានស្តីពីការឃុំខ្លួន", អនុម័តនៅថ្ងៃទី០៧ ធ្នូ ២០០៨ (**ឧបសម្ព័ន្ធ ក, ឯកសារភ្ជាប់ទី ១**) បានអនុញ្ញាតឲ្យសមាជិកនៃក្រុមមេធាវី និងជនជាប់ឃុំបញ្ជូនឯកសារទៅវិញទៅមក ក្នុងអំឡុងពេលចូលជួបសួរសុខទុក្ខ ដោយអាស្រ័យលើសេចក្តីសម្រេចរបស់ចៅក្រម ។

[37] ដីកាសម្រេចបន្តការឃុំខ្លួន, C20/4, កថាខណ្ឌទី ២៦ ។

[38] បណ្តឹងឧទ្ធរណ៍, C20/5/1, កថាខណ្ឌទី ២៣ ។

ការឃុំខ្លួន នឹងបំពានទៅលើសេចក្តីត្រូវការឲ្យមានមូលហេតុសមស្រប នៅក្នុងសេចក្តីសម្រេចរបស់តុលាការ[39] ។

១២. ដោយសារមានសេចក្តីសំអាងខាងលើ សហព្រះរាជអាជ្ញា ស្នើថាសារណារបស់មេធាវីការពារក្តី ទាក់ទងនឹងការចោទប្រកាន់អំពីការខ្វះមូលហេតុ គួរត្រូវបានបដិសេធចោល ។

## *ការពន្យារពេលនៃការឃុំខ្លួន*

១៣. វិធាន ៦៣.៦ និង ៦៣.៧ ចែងអំពីការពន្យារពេលឃុំខ្លួនជនត្រូវចោទជាទៀងទាត់ដោយស្វ័យប្រវត្តិ ។ បញ្ញត្តិបែបដូច្នេះ មិនមាននៅក្នុងឯកសារមូលដ្ឋាននៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី (“ICTY”) និងប្រទេសរ្វ៉ាន់ដា (“ICTR”) ហើយនិងតុលាការពិសេសសម្រាប់ប្រទេសស៊ីរ៉ាឡេអូន (“SCSL”) ទេ ។ ក៏ប៉ុន្តែ តុលាការពិសេសទាំងនោះប្រកាន់ខ្ជាប់ថាដើម្បីឲ្យការសុំដោះលែងជាថ្មីបានជោគជ័យ ចុងចម្លើយត្រូវតែបង្ហាញអំពី “ការផ្លាស់ប្តូរដ៏សំខាន់”[40] ។

---

[39] គេគួរតែនិយាយផងដែរ អំពីបញ្ហាដែលជនត្រូវចោទទទួលបាននូវសំណុំរឿងនៅក្នុងមន្ទីរឃុំឃាំងដែល សចស បានលើកឡើងនាពេលបច្ចុប្បន្ននេះ ។ សហព្រះរាជអាជ្ញា មិនជំទាស់ទៅនឹងកិច្ចការនោះទេ ។ ដើម្បីឆ្លើយតបទៅនឹងសំណើរបស់ក្រុមមេធាវី អៀង ធីរិទ្ធ និង នួន ជា ដែលចុះថ្ងៃទី២២ តុលា ២០០៨ និងថ្ងៃទី២៨ វិច្ឆិកា ២០០៨ រៀងៗខ្លួននោះ សចស បានសុំឲ្យលោកប្រធានមន្ទីរឃុំឃាំង នៅថ្ងៃទី ១១ ធ្នូ ២០០៨ ថាតើច្បាប់ចម្លងសំណុំរឿងអាចទុកនៅក្នុងបន្ទប់មួយដាច់ដោយឡែកនៃមន្ទីរឃុំឃាំង សម្រាប់ធ្វើការពិគ្រោះយោបល់ដោយមានការត្រួតពិនិត្យ ឬមួយក៏រក្សាទុកច្បាប់ចម្លងនៃឯកសារទាំងនោះនៅក្នុងទូតូចៗដែលអាចចាក់សោរបាន សម្រាប់ជនត្រូវចោទម្នាក់ៗ នៅខាងក្នុង ឬខាងក្រៅបន្ទប់ឃុំខ្លួនរបស់ពួកគេ បានដែរឬមួយយ៉ាងណា (អនុស្សរណៈផ្ទៃក្នុងការិយាល័យរបស់ សចស ផ្ញើជូនលោកប្រធានមន្ទីរឃុំឃាំងទាក់ទងនឹងការទទួលបាននូវសំណុំរឿងពីសំណាក់ជនត្រូវចោទ, **A 228/2**, ERN 00250695 (ភាសាអង់គ្លេស) ។ លោកប្រធានមន្ទីរឃុំឃាំង បានឆ្លើយតបថា មិនមានបន្ទប់នៅទំនេរសម្រាប់ទុកដាក់ច្បាប់ចម្លងនៃសំណុំរឿងទេ ហើយបើសម្រាប់ការពិគ្រោះយោបាល់ មានទូមួយចាក់សោរបានដោយមានប្អូនថតសម្រាប់ទុកដាក់ឯកសារខ្លះៗនៃសំណុំរឿង អាចទុកនៅក្នុងបន្ទប់ជនត្រូវចោទម្នាក់ៗបាន (*Réponse du Directeur du Centre de Détention aux Co-Juges d'Instruction relative à l'accès au dossier d'instruction par les personnes mises en examen*, ចុះថ្ងៃទី១៩ ធ្នូ ២០០៨, **A 228/2/I**, ERN 00251732 (ភាសាបារាំង) - មិនទាន់មានភាសាអង់គ្លេសនៅឡើយទេ បច្ចុប្បន្ននេះ ។

[40] *រដ្ឋអាជ្ញា ទល់នឹង Boskoski និង Tarculovski,* សំណុំរឿងលេខ IT-04-82-PT, សេចក្តីសម្រេចពាក់ព័ន្ធនឹងសារណាដែលកែប្រែថ្មីស្នើសុំដោះលែង Johan Tarculovski ជាបណ្តោះអាសន្ន, ចុះថ្ងៃទី១៧ មករា ២០០៧, កថាខណ្ឌទី ៩ ។

១៤. ស្រដៀងគ្នាទៅនឹងវិធានសម្រាប់អង្គជំនុំជម្រះនេះដែរ វិធាន ១១៨ នៃវិធានស្តីពីនីតិវិធី និងភស្តុតាងសម្រាប់តុលាការព្រហ្មទណ្ឌអន្តរជាតិ ("ICC") តម្រូវឱ្យអង្គបុរេជំនុំជម្រះរបស់ខ្លួនពិនិត្យឡើងវិញនូវការឃុំខ្លួនចុងចម្លើយបណ្តោះអាសន្ន យ៉ាងហោចណាស់រៀងរាល់ ១២០ ថ្ងៃម្តង ។ អង្គបុរេជំនុំជម្រះនៃតុលាការ ICC មាន "ករណីយកិច្ចឯករាជ្យ និងច្បាស់លាស់ [...] ដើម្បីធានាមិនឱ្យមានការឃុំខ្លួនបុគ្គលមុនពេលជំនុំជម្រះក្តី ក្នុងរយៈពេលមួយមិនសមស្រប"[41]។ អង្គបុរេជំនុំជម្រះ អាចកែប្រែសេចក្តីសម្រេចរបស់ខ្លួនស្តីពីការឃុំខ្លួនបាន "បើខ្លួន យល់ឃើញថា "មានការផ្លាស់ប្តូរកាលៈទេសៈដែលតម្រូវឱ្យខ្លួនធ្វើការកែប្រែ"[42] ។ នៅ តុលាការ ICC "អយ្យការទទួលបន្ទុកក្នុងការបង្ហាញភស្តុតាងពាក់ព័ន្ធទៅនឹងអត្ថិភាពនៃលក្ខខណ្ឌ [...] នៃការឃុំខ្លួនបណ្តោះអាសន្ន កំពុងបន្តនៅមាននៅឡើយ"[43] ។

១៥. នៅចំពោះមុខអង្គជំនុំជម្រះនេះ ការពន្យារពេលនៃការឃុំខ្លួនបណ្តោះអាសន្ន វិធានមិនបានតម្រូវឱ្យ ស.ច.ស ស្តាប់តាម សហព្រះរាជអាជ្ញា ឬភាគីដទៃទៀតនោះទេ លើកលែងតែជនត្រូវចោទ ។ វិធានទាំងនោះគ្រាន់តែចែងអំពីការតវ៉ា ដែលជនត្រូវចោទត្រូវដាក់ពាក្យ ។ អត្ថិភាពនៃការពន្យារពេលឃុំខ្លួនដោយស្វ័យប្រវត្តិបានផ្តល់ដល់ជនជាប់ឃុំនូវឱកាសមួយចំនួនដើម្បីបញ្ជាក់នូវជំហររបស់ខ្លួន ហើយបើសិនជាត្រូវបានទទួលយក អាចអនុវត្តនូវសិទ្ធិរបស់ខ្លួនក្នុងការប្តឹងឧទ្ធរណ៍ជំទាស់នឹងសេចក្តីសម្រេចដោយមានសំអាងហេតុនោះបាន[44] ។

---

[41] *ស្ថានភាពនៅសាធារណៈរដ្ឋប្រជាធិបតេយ្យកុងហ្គោ, នៅក្នុងសំណុំរឿងរវាង រដ្ឋអាជ្ញា ទល់នឹង Germaine Katanga និង Mathieu Ngudjolo Chui,* សេចក្តីសម្រេចពាក់ព័ន្ធនឹងសេចក្តីសង្កេតទៅលើការពិនិត្យឡើងវិញនៃការឃុំខ្លួនមុនពេលជំនុំជម្រះក្តី លើឈ្មោះ Germaine Katanga, សំណុំរឿងលេខ ICC-01/04-01/07, អង្គបុរេជំនុំជម្រះ, ចុះថ្ងៃទី០៩ កក្កដា ២០០៨, ទំព័រទី ៤ ។

[42] *ស្ថានភាពនៅសាធារណៈរដ្ឋប្រជាធិបតេយ្យកុងហ្គោ, នៅក្នុងសំណុំរឿងរវាង រដ្ឋអាជ្ញា ទល់នឹង Germaine Katanga និង Mathieu Ngudjolo Chui,* ការពិនិត្យឡើងវិញនូវសេចក្តីសម្រេចស្តីពីលក្ខខណ្ឌនៃការការឃុំខ្លួនមុនពេលជំនុំជម្រះក្តី លើឈ្មោះ Germaine Katanga, សំណុំរឿងលេខ ICC-01/04-01/07, អង្គបុរេជំនុំជម្រះ, ចុះថ្ងៃទី១៨ សីហា ២០០៨, ទំព័រទី ៦ ។

[43] *ស្ថានភាពនៅសាធារណៈរដ្ឋប្រជាធិបតេយ្យកុងហ្គោ, នៅក្នុងសំណុំរឿងរវាង រដ្ឋអាជ្ញា ទល់នឹង Germaine Katanga និង Mathieu Ngudjolo Chui,* សេចក្តីសម្រេចពាក់ព័ន្ធនឹងសេចក្តីសង្កេតទៅលើការពិនិត្យឡើងវិញនៃការឃុំខ្លួនមុនពេលជំនុំជម្រះក្តី លើឈ្មោះ Germaine Katanga, សំណុំរឿងលេខ ICC-01/04-01/07, អង្គបុរេជំនុំជម្រះ, ចុះថ្ងៃទី០៩ កក្កដា ២០០៨, ទំព័រទី ៤ ។

[44] វិធានផ្ទៃក្នុង, វិធាន ៦៣.៧ ។

## *ការយកចិត្តទុកដាក់ក្នុងការអនុវត្តន៍នូវដំណើរការនីតិវិធី និង លក្ខណ:វិនិច្ឆ័យដទៃទៀតក្នុងការកំណត់ការពន្យារពេលដ៏សមស្រប*

១៦. មេធាវីការពារក្ដីលើកឡើងថា ដោយសារតែ ស.ច.ស ត្រូវបានចោទដោយអះអាងថាខកខាន មិនបានបង្ហាញពីការយកចិត្តទុកដាក់ក្នុងការស៊ើបសួរប្រឆាំងនឹងដើមបណ្ដឹងឧទ្ធរណ៍ កាលពីឆ្នាំទៅមិញ ហើយជាលទ្ធផលខកខានមិនបានលើកហេតុផលលើភស្តុតាង នៅក្នុងសំណុំរឿងរបស់ខ្លួន លក្ខខណ្ឌតម្រូវនៃពេលវេលាសមស្របត្រូវបានបំពាន ហើយការឃុំខ្លួនបណ្ដោះអាសន្នមិនអាចត្រូវបានពន្យារតទៅទៀតបានទេ[45] ។ អបជ គួរតែបដិសេធសេចក្ដីអះអាងនេះចោល ដោយមានមូលហេតុដូចខាងក្រោម៖

### *ការយកចិត្តទុកដាក់ និង ការស៊ើបសួរ*

១៧. ដើម្បីគាំទ្រដល់ការអះអាងនេះ មេធាវីការពារក្ដីស្នើឲ្យអង្គជំនុំជម្រះនេះ យកបទដ្ឋាននៃការយកចិត្តទុកដាក់ ដែលពួកគាត់បានយោងពីមុនថាមានលក្ខណ: "ពិសេស" ឬ "គ្រប់គ្រាន់" ឬបើតាមពិតទៅ មានលក្ខណ:ដាច់ខាត មកអនុវត្តនៅក្នុងដំណើរការនីតិវិធីនៅចំពោះមុខ អ.វ.ត.ក ដែលមូលដ្ឋានរបស់វាត្រូវបានគេរកឃើញមានតែនៅក្នុងយុត្តិសាស្ត្ររបស់តុលាការអឺរ៉ុបសម្រាប់កិច្ចការសិទ្ធិមនុស្ស ("ECHR") ប៉ុណ្ណោះ ។ នៅពេលដែល ស.ច.ស បានយោងទៅដល់ "ការយកចិត្តទុកដាក់ហ្មត់ចត់" របស់ខ្លួននៅក្នុងការស៊ើបសួរ[46] មេធាវីការពារក្ដីស្វែងរកការអនុវត្តន៍នូវ "ការយកចិត្តទុកដាក់ពិសេស"[47] ឬ "ការយកចិត្តទុកដាក់គ្រប់គ្រាន់"[48]

---

[45] បណ្ដឹងឧទ្ធរណ៍, C20/5/1, កថាខណ្ឌទី ៣៩, ជាសេចក្ដីសន្និដ្ឋាននៃកថាខណ្ឌទី ២៦ ដល់ ៤៤ ។

[46] ដីកាសម្រេចបន្តការឃុំខ្លួន, C20/4, កថាខណ្ឌទី ៣៥ ។

[47] បណ្ដឹងឧទ្ធរណ៍, C20/5/1, កថាខណ្ឌទី ២៩-៣២ ។ នៅក្នុងករណីណាក៏ដោយ សេចក្ដីសំអាងអំពីបមាណី ("ការយកចិត្តទុកដាក់ពិសេស") អនុវត្តបានខ្ពស់ជាងបមាណី ("ការយកចិត្តទុកដាក់ហ្មត់ចត់") ទំនងជាមិនច្បាស់លាស់ទេនៅក្នុងបណ្ដឹងឧទ្ធរណ៍ ដែលបានពូតផ្គុំទៅដោយអង្គហេតុដែលមេធាវីបានបោះបង់ចោល ដូចជាការខុសគ្នាជាទ្រឹស្ដី និងមិនសំខាន់ នៅក្នុងកថាខណ្ឌទី ៣១ នៃបណ្ដឹងឧទ្ធរណ៍របស់ខ្លួន និងក្នុងកំណត់សម្គាល់ជើងទំព័រលេខ ២១ ។ ជាយថាហេតុ ពួកគាត់គ្រាន់តែជំទាស់ថា សចស មិនបង្ហាញអំពី "ការយកចិត្តទុកដាក់គ្រប់គ្រាន់" ("ការយកចិត្តទុកដាក់ហ្មត់ចត់" ឬមួយក៏ "ការយកចិត្តទុកដាក់ពិសេស") នៅក្នុងការស៊ើបសួររបស់ខ្លួនប្រឆាំងនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹងបណ្ដឹងឧទ្ធរណ៍របស់មេធាវីការពារក្ដី អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាសម្រេចអំពីការបន្តថិរវេលានៃការឃុំខ្លួន

ឬចុងបញ្ចប់ទៅគឺ បទដ្ឋាននៃការយកចិត្តទុកដាក់ដាច់ខាត[49] ។ សហព្រះរាជអាជ្ញា ស្នើថា បទដ្ឋានទាំងនេះ មានការពាក់ព័ន្ធ ឬជួយបានតិចតួចនៅក្នុងដំណើរការនីតិវិធីនៅចំពោះមុខ អ.វ.ត.ក ហើយបើគិតពីភាពជាក់លាក់និងភាពចាំបាច់វិញនោះ ការស៊ើបសួរនេះ តាមពិតបាន ដំណើរការ និងបានភស្តុតាងសំខាន់ៗដែលមានហេតុផល ។ បន្ថែមលើនេះ ការ អនុវត្តន៍ ទ្រឹស្តីនៃការពន្យារពេលដ៏សមស្រប ដែលបានបកស្រាយយ៉ាងត្រឹមត្រូវ មិនអាចគាំទ្រដល់ សំណើសុំដោះលែងនេះបានទេ ។

១៨. ពេលដែល ស.ច.ស ពិតជាបានយោងទៅដល់កាតព្វកិច្ចរបស់ខ្លួននៅក្នុងការស៊ើបសួរដោយ មានការយកចិត្តទុកដាក់ហ្មត់ចត់នោះ គេត្រូវតែមានការគិតគូរឱ្យបានគ្រប់ជ្រុងជ្រោយទៅលើ លក្ខណៈជាក់លាក់ពិតប្រាកដនៃការស៊ើបអង្កេតនៅក្នុងយុត្តាធិការនៃ អ.វ.ត.ក ។ ដើមបណ្តឹង ឧទ្ធរណ៍ ត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ (ការធ្វើមនុស្សឃាត ការ សម្លាប់រង្គាល ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទុក្ខបុកម្នេញ និង អំពើអមនុស្សធម៌ផ្សេងៗ ទៀត) ។ ដើមបណ្តឹងឧទ្ធរណ៍ កំពុងត្រូវបានស៊ើបអង្កេតថា បានរៀបចំផែនការ ញុះញង់ បញ្ជា ជួយ ឬជំរុញ បានប្រព្រឹត្ត ឬដោយមានការទទួលខុសត្រូវពីថ្នាក់លើចំពោះឧក្រិដ្ឋកម្ម ផ្សេងៗ ដែលប្រឆាំងនឹងមនុស្សជាតិ ។ បន្ថែមលើនេះ ដូចដែលបានរៀបរាប់នៅក្នុងដីកា សន្និដ្ឋានបញ្ជូន រឿងឱ្យស៊ើបសួរ និងនៅក្នុងការដាក់ឯកសារជាបន្តបន្ទាប់[50] ការដាក់បញ្ចូល

---

ជនត្រូវចោទ ។ មេធាវីបានជំទាស់ថា សចស បានអនុវត្តបមាណីមួយដែលខុស ពាក់ព័ន្ធនឹង ការយកចិត្តទុកដាក់ ដែលខ្វះភាពទាក់ទង និងភាពមិនផ្លាស់ប្តូរ ។

[48] បណ្តឹងឧទ្ធរណ៍, C20/5/1, កំណត់សម្គាល់ជើងទំព័រលេខ ២១ និងកថាខណ្ឌទី ៣៣-៣៥ និង ៣៦ ។ ក្នុងកំណត់សម្គាល់ជើងទំព័រ លេខ ២១ មេធាវី បានយោងទៅបមាណីនៃការយកចិត្តទុកដាក់ "ហ្មត់ចត់" និងទាំង "ពិសេស" ថាជា "ការយកចិត្តទុកដាក់គ្រប់គ្រាន់" ដើម្បីធ្វើការសន្និដ្ឋានលើនិយមន័យទាំងពីរ ។

[49] បណ្តឹងឧទ្ធរណ៍, C20/5/1, កថាខណ្ឌទី ៣៧ ។ មេធាវីបានលើកឡើងថា "សចស ត្រូវតែបង្ហាញថាខ្លួនបាន *បន្តធ្វើនូវ អ្វីៗគ្រប់យ៉ាង នៅក្នុងអំណាចរបស់ខ្លួន* ដើម្បីដឹកនាំ និងបញ្ចប់ការស៊ើបសួរប្រឆាំងនឹងជនត្រូវចោទ ដើម្បីឱ្យសំណុំរឿងនេះអាចដំណើរការឆ្ពោះទៅរក ការកាត់សេចក្តីឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន ឬមួយក៏ បទចោទនានាប្រឆាំងនឹងរូបគាត់គួរតែត្រូវបានបដិសេធចោល" ។ ការ សង្កត់ន័យបន្ថែមជាអក្សរទ្រេត ។ មិនមានបទប្បញ្ញត្តិណាមួយនៅក្នុងវិធានផ្ទៃក្នុង ឬនៅក្នុងយុត្តិសាស្ត្រអន្តរជាតិតម្រូវឱ្យមានការ អនុវត្តន៍នូវការយកចិត្តទុកដាក់មួយដែលដាច់ខាតបែបដូច្នោះទេ ។

[50] *ករណីរបស់ អៀង សារី*, ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងញត្តិស្នើសុំរបស់ អៀង សារី ស្តីពីសហកម្មឧក្រិដ្ឋកម្មរួម, សំណុំ រឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស, ចុះថ្ងៃទី១១ សីហា ២០០៨, ERN 00211956-70, **D 97/II** ។ សេចក្តី ចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹងបណ្តឹងឧទ្ធរណ៍របស់មេធាវីការពារក្តី អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាសម្រេចអំពី ការបន្តថិរវេលានៃការឃុំខ្លួន

នៅក្នុងបទចោទ ពី"ការប្រព្រឹត្តិ" គឺជាការចូលរួមចំណែករបស់ដើមបណ្តឹងឧទ្ធរណ៍នៅក្នុង សហកម្មឧក្រិដ្ឋកម្មរួម ក្នុងឋានៈជាសហចារី ដែលបណ្តាលឲ្យមានការប្រព្រឹត្តិបទឧក្រិដ្ឋ ជាក់ស្តែងជាច្រើន នៅពាសពេញប្រទេសកម្ពុជា និងនៅក្នុងអាណត្តិពេលវេលារបស់អង្គជំនុំជម្រះនេះ។ បទឧក្រិដ្ឋទាំងនេះ គឺឋិតនៅក្នុងចំណោមបទឧក្រិដ្ឋនានាដែលធ្ងន់ធ្ងរ និង ស្មុគស្មាញ ហើយជនត្រូវចោទ ប្រឈមមុខនឹងការជាប់ពន្ធនាគារអស់មួយជីវិតបើត្រូវបានកាត់ឲ្យជាប់ទោស ។

១៩. យន្តការនានាផ្នែកសិទ្ធិមនុស្សប្រចាំតំបន់ ដូចជាតុលាការ ECHR ជាដើម ដែលពិចារណាលើបញ្ហាដូចដែលពាក់ព័ន្ធស្តីពី ពេលវេលាសមស្រប និងការយកចិត្តទុកដាក់ហ្មត់ចត់ ហើយនិងលើសេចក្តីសម្រេចរបស់ពួកខ្លួន បង្កើតបានជាមូលដ្ឋានតែមួយគត់សម្រាប់ការដាក់ពាក្យរបស់ដើមបណ្តឹងឧទ្ធរណ៍ដោយផ្អែកលើទស្សនៈនេះ និងដំណើរការនៅក្នុងកាលៈទេសៈសំខាន់ខុសៗគ្នាពីអង្គជំនុំជម្រះនេះ ។ ជាដំបូង តុលាការ ECHR ដោះស្រាយលើករណីនានាដែលចេញមកពីយុត្តាធិការជាតិ ដោយមានមូលដ្ឋាននៅលើការជំនុំជម្រះក្តីលើបទឧក្រិដ្ឋថ្នាក់ជាតិនៅក្នុងកាលៈទេសៈដែលមិនមានទំនាស់គ្នា ។ ផ្ទុយទៅវិញ តុលាការដូចជា អ.វ.ត.ក ជាដើម គឺជាតុលាការដែលធ្វើឲ្យមានលក្ខណៈពិសេសជាអន្តរជាតិ ដែលធ្វើការជំនុំជម្រះលើបទឧក្រិដ្ឋអន្តរជាតិនានាដែលស្មុគស្មាញយ៉ាងខ្លាំង ។ សហព្រះរាជអាជ្ញា ស្នើថា អង្គបុរេជំនុំជម្រះត្រូវតែធ្វើការពិចារណាលើយុត្តិសាស្ត្ររបស់តុលាការ ECHR ដែលតម្រូវឲ្យមាន ការប្រុងប្រយ័ត្ន និងត្រូវពិនិត្យមើលឲ្យបានត្រឹមត្រូវនូវយុត្តិសាស្ត្ររបស់តុលាការព្រហ្មទណ្ឌ ពិសេសឬអចិន្ត្រៃយ៍នានា ដែលកំពុងធ្វើការកាត់សេចក្តីលើបទឧក្រិដ្ឋផ្សេងៗដែលមាន ភាពស្មុគស្មាញនិងទំហំស្មើគ្នា យកមកធ្វើជាគំរូតាម នៅលើបញ្ហាពាក់ព័ន្ធនានា ។ នៅក្នុង បណ្តឹងឧទ្ធរណ៍របស់ពួកខ្លួន មេធាវីការពារក្តីមិនបានយោងដល់យុត្តិសាស្ត្រពាក់ព័ន្ធទាំងនោះ ទេ[51] ។

---

សង្កេតបន្ថែមរបស់សហព្រះរាជអាជ្ញា ស្តីពីសហកម្មឧក្រិដ្ឋកម្មរួម, ចុះថ្ងៃទី៣១ ធ្នូ ២០០៨, **D 97/8** ERN 00268566-92(ភាសាអង់គ្លេស)។ ដីកាសម្រេចលើពាក្យសុំស្តីពីទម្រង់នៃការទទួលខុសត្រូវដែលមានឈ្មោះថា សហឧក្រិដ្ឋកម្មរួម, សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស, ចុះថ្ងៃទី១៦ កញ្ញា ២០០៨, **D 97/III,** ERN 00224208-09 (ភាសាអង់គ្លេស) ។

[51] *រដ្ឋអាជ្ញា ទល់នឹង Tihomir Blaskic,* សេចក្តីសម្រេចបដិសេធលើញត្តិស្នើសុំដោះលែងបណ្តោះអាសន្ន, សំណុំរឿងលេខ IT-94-14-, អង្គជំនុំជម្រះសាលាដំបូង, ចុះថ្ងៃទី២០ ធ្នូ ១៩៩៦ ។ *រដ្ឋអាជ្ញា ទល់នឹង Kanyabashi,* សេចក្តីសម្រេចលើញត្តិរបស់មេធាវី ស្នើសុំចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹងបណ្តឹងឧទ្ធរណ៍របស់មេធាវីការពារក្តី អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាសម្រេចអំពីការបន្តថិរវេលានៃការឃុំខ្លួន

សហព្រះរាជអាជ្ញា កត់សម្គាល់ថា ផ្ទុយទៅនឹងតុលាការនានាដែលសំណុំរឿងត្រូវ បញ្ជូនទៅកាន់តុលាការ ECHR អង្គជំនុំជម្រះនេះ ត្រូវធ្វើការជាមួយនឹងយន្តការស៊ើបអង្កេត ដែលបានបង្កើតឡើងជាពិសេសថ្មីមួយ ។ ការណ៍នេះបង្ហាញអំពីការប្រឈម និងភាព ស្មុគស្មាញ ដែលមានតែមួយ និងយ៉ាងជាក់លាក់ បានកាត់បន្ថយនូវការណែនាំដ៏មានប្រយោជន៍ តាមយុត្តិសាស្ត្រ ដែលដើមបណ្តឹងឧទ្ធរណ៍បានលើកឡើង ។

២០. លើសពីនេះទៀត ដូចដែលមានសំអាងនៅខាងក្រោម (សូមមើលកថាខណ្ឌទី **៣៥** ដល់ **៤៣**) ការទទួលបាននូវសំណុំរឿង បង្ហាញអំពីការជឿនលឿនដែលបានធ្វើឡើងនៅក្នុងការស៊ើបសួរ ហើយភស្តុតាងដែលបញ្ជាក់អំពីការទទួលខុសត្រូវរបស់ដើមបណ្តឹងឧទ្ធរណ៍ នៅក្នុងបទឧក្រិដ្ឋដែលបានចោទប្រកាន់ បានធ្វើឱ្យអន្តរាយដល់សារណារបស់មេធាវីការពារក្តី ។

*ការពន្យារពេលមិនសមស្រប*

២១. ជនត្រូវចោទត្រូវបានចាប់ខ្លួននៅថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០០៧ ។ នៅមុនផុតកំណត់ពេលក្នុង ដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៧[52] សចស បានចេញ "ដីកាសម្រេចអំពីការបន្តថិរវេលានៃឃុំខ្លួនបណ្តោះអាសន្ន" នៅថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០០៨ ដើម្បីបន្តការឃុំខ្លួនជនត្រូវចោទជាបណ្តោះអាសន្ន សម្រាប់រយៈពេលមិនលើសពីមួយឆ្នាំទៀត ដោយអនុលោមតាមវិធាន ៦៣.៦.ក[53] ។

---

ដោះលែងជនជាប់ចោទជាបណ្តោះអាសន្ន, សំណុំរឿងលេខ ICTR-96-15-T, អង្គជំនុំជម្រះសាលាដំបូង, ចុះថ្ងៃទី២១ កុម្ភៈ ២០០១, កថាខណ្ឌទី ១២ ។ *រដ្ឋអាជ្ញា ទល់នឹង Casimir Bizimungu, Justin Mugenzi, Jérome-Clément Bicamumpaka and Prosper Mugiraneze*, សេចក្តីសម្រេចលើពាក្យសុំរបស់ *Prosper Mugiraneze* ស្នើឱ្យបើកសវនាការ ឬបើមិនដូច្នោះទេ សុំឱ្យមានដំណោះស្រាយលើសំណើបដិសេធរបស់ខ្លួនដោយសារមានការបំពានលើសិទ្ធិរបស់ខ្លួនក្នុងការទទួលបាននូវកាត់សេចក្តីមួយដែលគ្មានការពន្យារពេលមិនសមស្រប, សំណុំរឿងលេខ ICTR-99-50, អង្គជំនុំជម្រះសាលាដំបូង, ចុះថ្ងៃទី០៣ វិច្ឆិកា ២០០៤ ។

[52] ដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន, ចុះថ្ងៃទី១៤ វិច្ឆិកា ២០០៧, C 20 ។

[53] ដីកាសម្រេចបន្តការឃុំខ្លួន, C20/4។

២២. នៅក្នុងដីកាសម្រេចបន្តការឃុំខ្លួន សហចៅក្រមស៊ើបអង្កេត ទទួលស្គាល់ថា ការកន្លងផុតទៅនៃពេលវេលាគឺទាក់ទងទៅនឹងការកំណត់ថា តើមូលដ្ឋាននៃការឃុំខ្លួនបណ្តោះអាសន្នដែលបានបន្តកំពុងតែនៅមាន ឬមួយយ៉ាងណា[54] ។ នៅពេលដែលថិរវេលាត្រូវបានតុលាការអន្តរជាតិនានាយកចិត្តទុកដាក់ពិចារណាថាជាកត្តាពាក់ព័ន្ធមួយ នៅក្នុងការកំណត់ពីភាពស្របច្បាប់នៃការឃុំខ្លួន មេធាវីការពារក្តីមិនបានបង្ហាញថាតើការឃុំខ្លួនក្នុងរយៈពេលមួយឆ្នាំនោះបានធ្វើឱ្យខូចខាតទៅលើសំណុំរឿងរបស់ដើមបណ្តឹងឧទ្ធរណ៍តាមរបៀបណា ដើម្បីការពារដល់ការជំនុំជម្រះក្តីប្រកបដោយភាពយុត្តិធម៌ និង/ឬ ដើម្បីបង្ហាញថាតើវាអាចផ្តល់យុត្តិកម្មលើការពិចារណាឡើងវិញអំពីការឃុំខ្លួន បានតាមរបៀបណានោះទេ ។

២៣. មាត្រា ១៤.៣.គ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ICCPR) ចែងថា "ក្នុងករណីនៃការសម្រេចវិនិច្ឆ័យទោសឧក្រិដ្ឋ ជនគ្រប់រូបមានសិទ្ធិក្នុងការទទួលបាននូវ [...] ការជំនុំជម្រះក្តីដោយឥតពន្យារពេលយូរ" ។ មាត្រា ៩.៣ នៃ ICCPR, មាត្រា ៧.៥ នៃអនុសញ្ញាស្តីពីសិទ្ធិមនុស្សសម្រាប់ទ្វីបអាមេរិក និងមាត្រា ៥.៣ នៃអនុសញ្ញាស្តីពីសិទ្ធិមនុស្សសម្រាប់ទ្វីបអឺរ៉ុប បានចែងថា ជនគ្រប់រូបដែលត្រូវបានឃុំខ្លួន មានសិទ្ធិក្នុងការទទួលបាននូវការជំនុំជម្រះក្តីក្នុង "រយៈពេលមួយដ៏សមស្រប" ។ គណៈកម្មាធិការផ្នែកសិទ្ធិមនុស្សធ្លាប់បានសម្រេចថា "អ្វីដែលបង្កើតបានជា "រយៈពេលមួយដ៏សមស្រប" គឺជាបញ្ហានៃការវាយតម្លៃលើករណីជាក់លាក់នីមួយៗ"[55] ។ នេះគឺជាគោលការណ៍ដែលគេបានបកស្រាយលើច្បាប់ព្រហ្មទណ្ឌអន្តរជាតិ ដែលត្រូវបានយល់ព្រមដោយតុលាការពិសេសសម្រាប់អតីតប្រទេសយូហ្គោស្លាវី និងប្រទេសរ៉្វាន់ដា[56] ។

---

[54] ដីកាសម្រេចបន្តការឃុំខ្លួន, C20/4, កថាខណ្ឌទី ៣៥ ។

[55] គណៈកម្មធិការសិទ្ធិមនុស្សរបស់ អសប, សេចក្តីជូនដំណឹងលេខ ៣៣៦/១៩៨៨, ករណី N. Fillastre ទល់នឹង ប្រទេសបូលីវី (ទស្សនៈត្រូវបានអនុម័តនៅថ្ងៃទី០៥ វិច្ឆិកា ១៩៩១), មាននៅក្នុងឯកសាររបស់ អសប GAOR A/47/40 ។

[56] *រដ្ឋអាជ្ញា ទល់នឹង Kanyabashi,* សេចក្តីសម្រេចលើញត្តិរបស់មេធាវី ស្នើសុំដោះលែងជនជាប់ចោទជាបណ្តោះអាសន្ន, ចុះថ្ងៃទី២១ កុម្ភៈ ២០០១, កថាខណ្ឌទី ១១ ។ *រដ្ឋអាជ្ញា ទល់នឹង Tihomir Blaskic,* សេចក្តីសម្រេចបដិសេធលើញត្តិស្នើសុំដោះលែងបណ្តោះអាសន្ន, អង្គជំនុំជម្រះសាលាដំបូង, ចុះថ្ងៃទី២០ ធ្នូ ១៩៩៦ ។

២៤. តុលាការ ICTY បានបង្កើតរឿងដូច្នេះដើម្បីធ្វើឲ្យមានលក្ខណៈសមស្របនៃរយៈពេលឃុំខ្លួនបណ្តោះអាសន្ន ដែលខ្លួនចាំបាច់ត្រូវវាយតម្លៃលើកាលៈទេសៈនៃករណីនីមួយៗ ដោយមានលក្ខណៈវិនិច្ឆ័យដូចតទៅ៖

ក. រយៈពេលនៃការឃុំខ្លួនដែលមានប្រសិទ្ធភាព

ខ. រយៈពេលនៃការឃុំខ្លួនដែលពាក់ព័ន្ធទៅនឹងប្រភេទនៃបទឧក្រិដ្ឋ

គ. ផលវិបាកតាមផ្លូវកាយ និងផ្លូវចិត្ត នៃការឃុំខ្លួនលើជនជាប់ឃុំ

ឃ. ភាពស្មុគស្មាញនៃសំណុំរឿង និងការស៊ើបអង្កេត

ង. ការប្រព្រឹត្តិទៅនៃដំណើរការនីតិវិធីទាំងមូល[57] ។

២៥. តុលាការ ICTR បានអនុម័តលើការសាកល្បងស្រដៀងគ្នាមួយ នៅក្នុងការវាយតម្លៃលើភាពសមស្របនៃការឃុំខ្លួនបណ្តោះអាសន្ន ហើយដោយមានកាលៈទេសៈនៃសំណុំរឿងនានានៅចំពោះមុខខ្លួន គឺនៅមិនទាន់ដែលបានរកឃើញនូវរយៈពេលនៃការឃុំខ្លួនបណ្តោះអាសន្នណាមួយដែលមិនសមស្របនៅឡើយទេ[58] ។

២៦. ទោះបីជាបទចោទប្រកាន់នានាដែលធ្វើដោយ អ.វ.ត.ក មានភាពធ្ងន់ធ្ងរយ៉ាងណាក៏ដោយក៏វិធាន ៦៣ បានចែងអំពីកិច្ចការពារមួយចំនួនដើម្បីធានាថាការឃុំខ្លួនបណ្តោះអាសន្ន គឺត្រូវមានរយៈពេលខ្លីតាមដែលអាចធ្វើទៅបាន ។ វិធាន ៦៣.៦ និង ៦៣.៧ បានចែងថា គ្មានជនជាប់ចោទណាម្នាក់នៅចំពោះមុខ អ.វ.ត.ក អាចត្រូវបានឃុំខ្លួនបណ្តោះអាសន្ន ជាសរុប

---

[57] *រដ្ឋអាជ្ញា ទល់នឹង Tihomir Blaskic,* សេចក្តីសម្រេចបដិសេធលើញត្តិស្នើសុំដោះលែងបណ្តោះអាសន្ន, សំណុំរឿងលេខ IT-94-14-, អង្គជំនុំជម្រះសាលាដំបូង, ចុះថ្ងៃទី២០ ធ្នូ ១៩៩៦ ។

[58] ជាឧទាហរណ៍ សូមអាន៖ *រដ្ឋអាជ្ញា ទល់នឹង Casimir Bizimungu, Justin Mugenzi, Jérome-Clément Bicamumpaka and Prosper Mugiraneze,* សេចក្តីសម្រេចលើពាក្យសុំរបស់ *Prosper Mugiraneze* ស្នើឲ្យបើកសវនាការ ឬបើមិនដូច្នោះទេសុំឲ្យមានដំណោះស្រាយលើសំណើបដិសេធរបស់ខ្លួន ដោយសារមានការបំពានលើសិទ្ធិរបស់ខ្លួនក្នុងការទទួលបាននូវកាត់សេចក្តីមួយដែលគ្មានការពន្យារពេលមិនសមស្រប, សំណុំរឿងលេខ ICTR-99-50, អង្គជំនុំជម្រះសាលាដំបូង, ចុះថ្ងៃទី០៣ វិច្ឆិកា ២០០៤, កថាខណ្ឌទី ២៦ ។

លើសពី ៣ (បី) ឆ្នាំបានទេ[59] ។ កិច្ចការពារទាំងនេះ មិនមាននៅចំពោះមុខតុលាការ ICTR និង ICTY ទេ ។ លើសពីនេះដូចដែលបានលើកឡើងនៅក្នុងកថាខណ្ឌទី ១៣ នៃចម្លើយតបបច្ចុប្បន្ននេះ វិធាន ៦៣.៦ និង ៦៣.៧ បានចែងអំពីការពន្យារពេលនៃការបន្តការឃុំខ្លួនជនត្រូវចោទជាស្វ័យប្រវត្តិនិងដោយទៀងទាត់ (យ៉ាងហោចណាស់មួយឆ្នាំម្តង)។ ហេតុដូច្នេះ វិធានផ្ទៃក្នុងបានប្រមើលមើលយ៉ាងច្បាស់ថា គ្មានជនត្រូវចោទណាម្នាក់នឹងត្រូវឋិតនៅ ក្រោមការឃុំខ្លួនបណ្តោះអាសន្ន ដោយមានរយៈពេលមិនសមស្របនោះទេ ។

២៧. នៅក្នុងការវាយតម្លៃលើភាពសមស្របនៃការឃុំខ្លួនបណ្តោះអាសន្ន តុលាការ ICTY បានពិចារណាយ៉ាងជាប់លាប់ អំពីរយៈពេលនៃការឃុំខ្លួន ដែលមានរយៈពេលវែងជាងរយៈពេលដ៏សមស្របឆ្ងាយណាស់ ដោយសារភាពធ្ងន់ធ្ងរនៃបទឧក្រិដ្ឋដែលបានប្រព្រឹត្ត[60] ។ នៅក្នុងករណីបច្ចុប្បន្ននេះ ដែលមេធាវីការពារក្តីបានដាក់សំណុំរឿងទៅតុលាការ ECHR មានពាក់ព័ន្ធទៅនឹងឧក្រិដ្ឋកម្មដែលមានលក្ខណៈមិនសូវជាធ្ងន់ធ្ងរជាប់មកជាមួយប៉ុន្មាន និងរយៈពេលនៃការឃុំខ្លួនដែលលើសយ៉ាងច្រើនពីរយៈពេលសម្រាប់ឃុំខ្លួនជនត្រូវចោទ ដូច្នោះហើយ គឺវាមិនអាចប្រៀបធៀបបានទៅនឹងសំណុំរឿងដែលមាននៅក្នុងដៃ[61] ។ ដូចដែលតុលាការ ICTY

---

[59] វិធាន ៦៣.៦ បានបញ្ញត្តអំពីថិរវេលាដំបូងនៃការឃុំខ្លួនបណ្តោះអាសន្ន ចំពោះបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ ដែលមិនលើសពីមួយឆ្នាំទេ ។ វិធាន ៦៣.៦ បានចែងថា សចស អាចពន្យារពេលការឃុំខ្លួនបណ្តោះអាសន្នបន្ថែមម្តងបានមួយឆ្នាំ ។ វិធាន ៦៣.៧ បានដាក់កំរិត សចស ឱ្យពន្យារពេលបែបដូច្នេះបានតែពីរដងប៉ុណ្ណោះ ។

[60] ជាឧទាហរណ៍, *រដ្ឋអាជ្ញា ទល់នឹង Blaskic,* សេចក្តីសម្រេចបដិសេធលើញត្តិស្នើសុំដោះលែងបណ្តោះអាសន្ន, អង្គជំនុំជម្រះសាលាដំបូងរបស់តុលាការ ICTY, ចុះថ្ងៃទី២០ ធ្នូ ១៩៩៦ *រដ្ឋអាជ្ញា ទល់នឹង Mrda,* សេចក្តីសម្រេចលើសំណើរបស់ Darko Marda ស្នើសុំដោះលែងបណ្តោះអាសន្ន, សំណុំរឿងលេខ IT-02-59-PT, អង្គជំនុំជម្រះសាលាដំបូងទី II របស់តុលាការ ICTY, ចុះថ្ងៃទី១៥ មេសា ២០០២ ។

[61] *ករណីរបស់ Tomasi ទល់នឹង ប្រទេសបារាំង,* សេចក្តីសម្រេច, តុលាការអឺរ៉ុប, ពាក្យសុំលេខ ១២៨៥០/៨៧, ចុះថ្ងៃទី២៧ ធ្នូ ១៩៩២, កថាខណ្ឌទី ៨៩ ។ (ការឃុំខ្លួនបណ្តោះអាសន្នចំនួន ៥ឆ្នាំ និង ៧ខែ ពីបទសង្ស័យថាបានប្រព្រឹត្តឃាតកម្មដោយបានគិតទុកជាមុន ។ ដោយថាហេតុ អ្នកដាក់ពាក្យសុំត្រូវបានដោះលែងឱ្យរួចខ្លួន) ។ *ករណីរបស់ Wemhoff ទល់នឹង ប្រទេសអាល្លឺម៉ង់,* សេចក្តីសម្រេច, តុលាការអឺរ៉ុប, ពាក្យសុំលេខ ២១២២/៦៤, ចុះថ្ងៃទី២៧ មិថុនា ១៩៦៨ ។ (ការឃុំខ្លួនមុនពេលជំនុំជម្រះក្តីចំនួន ៣ឆ្នាំ ពីបទសង្ស័យថាបាន ប្រព្រឹត្តអំពើបន្លំបោកប្រាស់មួយចំនួន ដែលជាថិរវេលាមួយដែលតុលាការបានធ្វើការសម្រេចយ៉ាងសមស្រប) ។ *ករណីរបស់ Stögmüller ទល់នឹង ប្រទេសអូទ្រីស,* សេចក្តីសម្រេច, តុលាការអឺរ៉ុប, ពាក្យសុំលេខ ១៦០២/៦២, ចុះថ្ងៃទី១០ វិច្ឆិកា ១៩៦៩ ។ (ការឃុំខ្លួនមុនពេលជំនុំជម្រះក្តីចំនួន ២ឆ្នាំ ពីបទសង្ស័យថាបានប្រព្រឹត្តអំពើបន្លំបោកប្រាស់ដ៏ធ្ងន់ធ្ងរ) ។ *ករណីរបស់ Matznetter ទល់នឹង ប្រទេសអូទ្រីស,* សេចក្តីសម្រេច, តុលាការអឺរ៉ុប, ពាក្យសុំលេខ ២១៧៨/៦៤, ចុះថ្ងៃទី១០ វិច្ឆិកា ១៩៦៩ ។

ធ្លាប់បានធ្វើការកត់សម្គាល់រួចមក តុលាការ ECHR មិនដែលបានរកឃើញថាមានការបំពានលើមាត្រា ៥.៣ នៃអនុសញ្ញាសម្រាប់ទ្វីបអឺរ៉ុប នៅក្នុងករណីផ្សេងៗដែលពាក់ព័ន្ធនឹងរយៈពេលនៃការឃុំខ្លួនបណ្តោះអាសន្ន ដែលមានរយៈពេលវែងជាងរយៈពេលនៃសំណុំរឿងដែលមាននៅក្នុងដែនេះទេ[62] ។ ដោយសារភាពធ្ងន់ធ្ងរនៃបទឧក្រិដ្ឋដែលបានចោទប្រកាន់ ហើយនិងកិច្ចការពារនានាដែលមាននៅក្នុងវិធានផ្ទៃក្នុងប្រឆាំងនឹងការឃុំខ្លួនដែលគ្មានកំណត់ច្បាស់លាស់ នោះទើបការឃុំខ្លួនបណ្តោះអាសន្នដែលមានរយៈពេលមួយឆ្នាំ មិនមែនមិនសមស្របនោះទេ ។

២៨. តុលាការ ICTR បានសម្រេចថា ភាពស្មុគ្រស្មាញនៃបញ្ហាខាងអង្គហេតុ និងអង្គច្បាប់ ដែលបានលើកឡើងនៅក្នុងរឿងក្តីមួយគឺមានការជាប់ទាក់ទងគ្នាទៅនឹងសំណួរថា តើ រយៈពេលនៃចំណាត់ការនីតិវិធីវាស្របគ្នាជាមួយនឹង " ពេលវេលាសមស្រប" ដែលបានតម្រូវដែរឬទេ[63] និងថា តើបានចាត់ទុកភាពស្មុគ្រស្មាញនៃរឿងក្តីទាំងឡាយថាមានជាប់ទាក់ទងគ្នា ដែរឬទេ ក្នុងការសម្រេចអំពីរយៈពេលនៃការឃុំខ្លួនបណ្តោះអាសន្នដល់ទៅបួនឆ្នាំកន្លះ និងប្រាំឆ្នាំជាការ

---

(ការឃុំខ្លួនមុនពេលជំនុំជម្រះក្តីចំនួន ២៥ខែ ពីបទសង្ស័យថាបានប្រព្រឹត្តអំពើបន្លំបោកប្រាស់) ។ *ករណីរបស់ Celleja ទល់នឹង ប្រទេសម៉ាល់តា,* សេចក្តីសម្រេច, តុលាការអឺរ៉ុប, ពាក្យសុំលេខ ៧៥២៧៤/០១, ចុះថ្ងៃទី០៧ មេសា ២០០៥ ។ (ការឃុំខ្លួនបណ្តោះអាសន្នចំនួន ៤ឆ្នាំ និង ១០ខែ ពីបទសង្ស័យថាបានសមគំនិតប្រព្រឹត្តអំពើឃាតកម្ម) ។ *ករណីរបស់ Letellier ទល់នឹង ប្រទេសបារាំង,* សេចក្តីសម្រេច, តុលាការអឺរ៉ុប, ពាក្យសុំលេខ ១២៣៦៩/៨៦, ចុះថ្ងៃទី២៦ មិថុនា ១៩៩១ ។ Letellier ត្រូវបានឃុំខ្លួនមុនពេលជំនុំជម្រះក្តីចំនួន ២ឆ្នាំ និង ៩ខែ ពីបទសង្ស័យថាបានសមគំនិតប្រព្រឹត្តអំពើឃាតកម្ម ។ *ករណីរបស់ Assenov ទល់នឹង ប្រទេសប៊ុលហ្គារី,* សេចក្តីសម្រេច, តុលាការអឺរ៉ុប, ពាក្យសុំលេខ ២៤៧៦០/៩៤, ចុះថ្ងៃទី២៨ តុលា ១៩៩៨ (២ឆ្នាំ នៅក្នុងការឃុំខ្លួនមុនពេលជំនុំជម្រះក្តី ពីបទសង្ស័យថាបានគាស់ចូលលួច, កាត់ឱ្យជាប់ទោសពន្ធនាគារចំនួន ២ឆ្នាំ ។

[62] *រដ្ឋអាជ្ញា ទល់នឹង Blaskic,* សេចក្តីសម្រេចបដិសេធលើញត្តិស្នើសុំដោះលែងបណ្តោះអាសន្ន, អង្គជំនុំជម្រះសាលាដំបូងរបស់តុលាការ ICTY, ចុះថ្ងៃទី២០ ធ្នូ ១៩៩៦ ។

[63] *ករណីរឿងរដ្ឋអាជ្ញា ទល់នឹង Kanyabashi,* ដីកាសម្រេចលើញត្តិតវ៉ារបស់មេធាវីការពារក្តីដែលស្នើសុំឱ្យដោះលែងជនជាប់ចោទជាបណ្តោះអាសន្ន, សំណុំរឿងលេខ ICTR 96-15-T, របស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី ២១ កុម្ភៈ ២០០១, កថាខណ្ឌទី១២។ ក្នុងករណីរឿងនេះ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា ការឃុំខ្លួនជនជាប់ចោទជាបណ្តោះអាសន្នចំនួន៥ឆ្នាំ គឺជាការសមស្រប គឺដោយសារតែ *ក្នុងចំណោមបញ្ហាដទៃទៀតជាច្រើន* លក្ខណៈស្មុគ្រស្មាញនៃបញ្ហាខាងអង្គហេតុ និងអង្គច្បាប់ ដែលបានលើកឡើងនៅក្នុងករណីរឿងនោះ។

សមហេតុសមផលនោះ[64] ។ ក្នុងការដោះស្រាយលើបញ្ហាអំពីថាតើរយៈពេលឃុំខ្លួនបណ្ដោះអាសន្នរបស់ជនត្រូវចោទហួសពី "រយៈពេលសមស្រប" ដែរឬទេនោះ មេធាវីការពារក្ដីបានផ្អែកទៅលើករណីរឿងក្ដីរបស់តុលាការសិទ្ធិមនុស្សនៃទ្វីបអឺរ៉ុបក្នុងរឿង *Wemhoff ទល់នឹង ប្រទេសអាល្លឺម៉ង់* [65]។ ថ្វីត្បិតតែមានការប្រៀបធៀបទៅ ថាជាបទល្មើសដែលស្រាលជាង និងដែលមានរយៈពេលនៃការឃុំខ្លួនបណ្ដោះអាសន្នយូរជាង នៃករណីនៃរឿងក្ដីនោះ ដែលតុលាការ ECHR បានសម្រេចថា រយៈពេលនៃការឃុំខ្លួនបណ្ដោះ អាសន្ននោះជាការសមហេតុសមផល ដោយសារតែលក្ខណៈស្មុគ្រស្មាញនៃករណីរឿងនោះ និងដែលបានសម្រេចនៅទីនោះដើម្បីកុំឱ្យមានការរំលោភបំពានទៅលើមាត្រា៥.៣ អនុសញ្ញានៃទ្វីបអឺរ៉ុបស្ដីពីសិទ្ធិមនុស្ស[66]។ ជនត្រូវចោទបានប្រឈមមុខទៅនឹងបទចោទជាច្រើនពាក់ព័ន្ធទៅនឹងទម្រង់នៃការទទួលខុសៗគ្នា នៃការចូលរួមរបស់គាត់ក្នុងសហកម្មឧក្រិដ្ឋកម្មរួមមួយដែលត្រូវបានចោទប្រកាន់ពីការទទួលខុសត្រូវនៅក្នុងបណ្ដាញឧក្រិដ្ឋកម្មមួយ ដែលមានលក្ខណៈទូលំទូលាយ និងជាប្រព័ន្ធសម្រាប់រយៈពេលជាងបីឆ្នាំកន្លះ។ ដោយយល់ឃើញអំពី លក្ខណៈដ៏ស្មុគ្រស្មាញដោយឡែកខុសពីគេនៃឧក្រិដ្ឋកម្មទាំងនេះ ការឃុំខ្លួនបណ្ដោះអាសន្ន រយៈពេលមួយ(១)ឆ្នាំរបស់ជនត្រូវចោទ គឺមិនមែនមិនសមស្របនោះទេ។

២៩. ដើមបណ្ដឹងឧទ្ធរណ៍បានខកខានមិនបានចង្អុលបង្ហាញអំពីភាពដែលអាចអនុវត្តបាននៃបទដ្ឋាននៃ " ការយកចិត្តទុកដាក់ជាពិសេស" ឬ "ការយកចិត្តទុកដាក់យ៉ាងគ្រប់គ្រាន់" ចំពោះដំណើរ

---

[64] *ករណីរឿងរដ្ឋអាជ្ញា ទល់នឹង Casimir Bizimungu ,Justin Mugenzi, Jérome-Clément Bicamumpaka និង Prosper Muziranege,* ដីកាសម្រេចលើពាក្យសុំរបស់ Prosper Mugiraneze ដែលស្នើសុំឱ្យមានការបើកសវនាការមួយ ឬ ឱ្យមានការដោះស្រាយសំណងជួសជុលផ្សេងទៀតដូចក្នុងញត្តិតវ៉ាសុំឱ្យលើកលែងការចោទប្រកាន់របស់ខ្លួន ព្រោះដោយមានការរំលោភលើសិទ្ធិត្រូវបានទទួលការជំនុំជម្រះក្ដី ដោយគ្មានការពន្យាពេលដោយមិនសមស្របរបស់ខ្លួន, សំណុំរឿងលេខ ICTR 99-50-T, របស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី ៣ វិច្ឆិកា ២០០៤។ និងក្នុង *ករណីរឿងរដ្ឋអាជ្ញា ទល់នឹង Kanyabashi,* ដីកាសម្រេចលើញត្តិតវ៉ារបស់មេធាវីការពារក្ដីដែលស្នើសុំឱ្យដោះលែងជនជាប់ចោទជាបណ្ដោះអាសន្ន, សំណុំរឿងលេខ ICTR 96-15-T, របស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី ២១ កុម្ភៈ ២០០១, កថាខណ្ឌទី១២, រៀងៗខ្លួន។

[65] បណ្ដឹងឧទ្ធរណ៍ C20/5/1, លេខយោងជើងទំព័រលេខ១៧។

[66] *ករណីរឿងក្ដីរបស់ Wemhoff ទល់នឹង ប្រទេសអាល្លឺម៉ង់* សាលក្រម, តុលាការអឺរ៉ុប, ឧទ្ធរណ៍។ លេខ 2122/64 ចុះថ្ងៃទី២៧ មិថុនា ១៩៦៨, កថាខណ្ឌទី១៧។

ការនៃនីតិវិធីនៅចំពោះមុខ អ.វ.ត.ក ឬចំពោះលក្ខណៈវិនិច្ឆ័យដើម្បីកំណត់អត្តសញ្ញាណ និងការធ្វើឱ្យឃើញអំពីភាពខុសគ្នានៃសញ្ញាណនីមួយៗក្នុងចំណោមសញ្ញាណទាំងនោះទេ។ ជាងនេះទៅទៀត ភស្តុតាងដែលសហចៅក្រមស៊ើបអង្កេតប្រមូលបានគ្របដណ្តប់ទៅលើគ្រប់ទម្រង់ និងប្រភេទទាំងអស់នៃការចូលរួមចំណែករបស់ដើមបណ្តឹងឧទ្ធរណ៍នៅក្នុងបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលត្រូវបានចោទប្រកាន់ រួមមាន ភស្តុតាងកពីទីកន្លែងកើតហេតុនៃបទល្មើស, ភស្តុតាងដែលភ្ជាប់ទីកន្លែងកើតហេតុទៅនឹងរចនាសម្ព័ន្ធនៃការដឹកនាំ ដែលដើមបណ្តឹងឧទ្ធរណ៍បានអនុវត្តនូវសិទ្ធិអំណាចក្នុងការបញ្ជា, ភស្តុតាងដែលគាំទ្រអំពីការចូលរួមនៅក្នុងសហកម្មឧក្រិដ្ឋកម្មរួម, ភស្តុតាងដែលគាំទ្រអំពីធាតុផ្សំនានាខាងយុត្តាធិការដូចជា អំពីការវាយប្រហារដែលមានលក្ខណៈទូលំទូលាយ និងជាប្រព័ន្ធប្រឆាំងនឹងប្រជាជនស៊ីវិលជាដើម។ សហចៅក្រមស៊ើបអង្កេតបាននិងកំពុងតែចេញដីកាចាត់ឱ្យស៊ើបសួរជំនួសជាច្រើន និងប្រមូលបាននូវចម្លើយសាក្សីចំនួនជាងមួយរយនាក់ ព្រមទាំងភស្តុតាងដែលគាំទ្រចំពោះប្រភេទផ្សេងៗនៃភស្តុតាងទាំងនោះ[67] ហេតុដូចនេះ សហចៅក្រមស៊ើបអង្កេតបានអនុវត្តនូវការយកចិត្តទុកដាក់ហ្មត់ចត់នៅក្នុងការដឹកនាំការស៊ើបសួររបស់ខ្លួនហើយ។

៣០. សហព្រះរាជអាជ្ញា សន្និដ្ឋានថា មេធាវីការពារក្តីមិនបានបង្ហាញឱ្យឃើញថា តើរយៈពេលនៃការឃុំខ្លួននោះបានធ្វើឱ្យខូចខាតដល់ករណីរឿងក្តីរបស់គាត់យ៉ាងណានោះ ដើម្បីការពារដល់ការជំនុំជម្រះក្តីប្រកបដោយភាពយុត្តិធម៌ និង/ឬក៏ ដើម្បីបង្ហាញថាតើវាអាចផ្តល់យុត្តិកម្មលើការពិចារណាឡើងវិញអំពីការឃុំខ្លួនបានតាមរបៀបណានោះទេ។ ដោយផ្អែកទៅលើកាលៈទេសៈនានានៃករណីរឿងក្តី និងយុត្តិសាស្ត្រអន្តរជាតិ រយៈពេលនៃការឃុំខ្លួនបណ្តោះ-អាសន្នរបស់ដើមបណ្តឹងឧទ្ធរណ៍គឺសមស្របតាមមាត្រា៩.៣ នៃអនុសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និង សិទ្ធិនយោបាយ ។ ជនត្រូវចោទត្រូវបានដាក់ឱ្យស្ថិតនៅក្នុងការឃុំខ្លួនបណ្តោះអាសន្នសម្រាប់រយៈពេលដ៏សមស្របមួយ ដោយសារតែមានការចោទប្រកាន់អំពីបទឧក្រិដ្ឋធ្ងន់ធ្ងរ, លក្ខណៈស្មុគស្មាញនៃករណីរឿងក្តី និងកម្រិតនៃការស៊ើបសួរដែលកំពុងតែអនុវត្តដោយសហចៅក្រមស៊ើបអង្កេត។ ការថែរក្សាការពារផ្សេងៗដែលមាននៅក្នុងវិធានផ្ទៃក្នុងបានចែង

---

[67] សូមអានខាងក្រោម, កថាខណ្ឌទី៣៥-៤៣ នៃចម្លើយតបនេះ។

អំពី ការកំរិតទៅលើរយៈពេលនៃការឃុំខ្លួនអាចអនុញ្ញាតឲ្យធ្វើបាន និងថែងអំពីការពិនិត្យឡើងវិញលើការឃុំខ្លួនបណ្តោះអាសន្នដែលធ្វើឲ្យលែងមានការព្រួយបារម្ភអំពី រយៈពេលនៃការឃុំខ្លួនបណ្តោះអាសន្នដែលនឹងត្រូវអនុញ្ញាតដើម្បីក្លាយទៅជាភាពមិនសមស្រប ។ ដោយមូលហេតុដូចខាងលើនេះ សហព្រះរាជអាជ្ញា សូមស្នើឲ្យអង្គបុរេជំនុំជម្រះបដិសេធចោលនូវបណ្តឹងឧទ្ធរណ៍របស់មេធាវីការពារក្តី។

## *គ្មានការរំលោភទៅលើសិទ្ធិនៅស្ងៀមមិនឆ្លើយតបនោះទេ*

៣១. ដើមបណ្តឹងឧទ្ធរណ៍បានលើកឡើងថាសហចៅក្រមស៊ើបអង្កេត រំលោភសិទ្ធិ ឬបានរំលោភជាក់ស្តែងចំពោះសិទ្ធិក្នុងការនៅស្ងៀមមិនឆ្លើយតបរបស់ដើមបណ្តឹងឧទ្ធរណ៍និង "បានបន្ទោសដើមបណ្តឹងឧទ្ធរណ៍ (...) ដែលបានប្រកាន់យកនូវអាកប្បកិរិយាមួយដែលមិនជួយធ្វើឲ្យដំណើរការនៃនីតិវិធីធ្វើទៅបានដោយឆាប់រហ័សនោះទេ"[68] ។ ហេតុដូចនេះ មេធាវីការពារក្តីបានលើកឡើងថា ដីកាសម្រេចស្តីពីការបន្តថិរវេលានៃការឃុំខ្លួនគួរតែត្រូវបានច្រានចោលដោយសារលែងមានភាពស្របច្បាប់តទៅទៀតហើយ។

៣២. គ្មានការផ្តល់អំពីអង្គហេតុសម្រាប់គាំទ្រដល់សេចក្តីថ្លែងនេះទេ ដែលហាក់ដូចជាត្រូវបានផ្អែកទៅលើការភ័ន្តច្រឡំមួយនៅក្នុងការអានដីកាសម្រេចបន្តថិរវេលា។ សហចៅក្រមស៊ើបអង្កេតគ្រាន់តែបានពោលអះអាងថា ការអនុវត្តនូវសិទ្ធិរបស់ដើមបណ្តឹងឧទ្ធរណ៍ដែលត្រូវបានទទួលស្គាល់ និង ដែលមិនអាចប្រកែកបាន "គឺមិនបានជួយដល់ចំណាត់ការដ៏ឆាប់រហ័សទេ"[69] ។ នេះគឺគ្រាន់តែជាអង្គហេតុមួយប៉ុណ្ណោះ ។ ការពោលអះអាងនេះ មិនបានបញ្ជាក់ថា សហចៅក្រមស៊ើបអង្កេត បានសម្រេចឲ្យអនុវត្តសិទ្ធិនេះដោយដើមបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងរូបគាត់នោះទេ។ សហព្រះរាជអាជ្ញាសង្កត់ធ្ងន់ថា សិទ្ធិរបស់ជនត្រូវចោទក្នុងការនៅស្ងៀមមិនឆ្លើយតប ត្រូវបានការពារដោយច្បាប់ជាធរមាននៅចំពោះមុខតុលាការនេះ និង ជាបទដ្ឋាន

[68] បណ្តឹងឧទ្ធរណ៍, ឯកសារលេខ C20/5/1 កថាខណ្ឌទី៤៥-៥៦ ជាពិសេសទី៤៧។ កថាខណ្ឌទាំងនេះមិនច្បាស់លាស់ទេទាក់ទងទៅនឹងការចោទប្រកាន់អំពី *ការរំលោភបំពាន ឬ ប៉ុនប៉ងរំលោភបំពាន*ទៅលើសិទ្ធិនៅស្ងៀមមិនឆ្លើយ។

[69] ដីកាបន្តការឃុំខ្លួន, ឯកសារលេខ C20/4, កថាខណ្ឌទី៣៧។

អន្តរជាតិមួយដែលតុលាការនេះត្រូវជាប់កាតព្វកិច្ចអនុវត្តតាមផង ។ ដោយចៅក្រមអព្យាក្រិតគឺជាអ្នកដឹកនាំក្នុងការស្វែងរកការពិតនោះ សហចៅក្រមស៊ើបអង្កេតត្រូវតែប្រមូលទាំងភស្តុតាងដាក់បន្ទុក និងភស្តុតាងដោះបន្ទុក។ តាមការសន្មតជនត្រូវចោទម្នាក់ៗអាច-ជួយដល់សហចៅក្រមស៊ើបអង្កេតក្នុងការរកឃើញនូវភស្តុតាងដោះបន្ទុក -បានល្អប្រសើរជាងជនណាផ្សេងទៀតទាំងអស់។ ក្នុងករណីមិនមានកិច្ចសហប្រតិបត្តិការនេះទេ ការស៊ើបសួរ គឺចាំបាច់ត្រូវតែប្រើរយៈពេលយូរជាងការដែលមានដើមបណ្តឹងឧទ្ធរណ៍ជាអ្នកផ្តល់ភស្តុតាងនេះ។

៣៣. អាស្រ័យហេតុនេះ សហព្រះរាជអាជ្ញា សូមស្នើឱ្យអង្គបុរេជំនុំជម្រះបដិសេធចោលនូវការលើកឡើងរបស់ដើមបណ្តឹងឧទ្ធរណ៍ដែលថា សហចៅក្រមស៊ើបអង្កេត បានខំស្វែងរកដើម្បីរំលោភ ឬបានរំលោភសិទ្ធិក្នុងការនៅស្ងៀមមិនឆ្លើយតបរបស់ដើមបណ្តឹងឧទ្ធរណ៍។

## IV. ការឃុំខ្លួនបណ្តោះអាសន្ន
## អង្គហេតុ និងសំអាង

៣៤. មានលក្ខខណ្ឌចំនួនពីរដែលបានចែងនៅក្នុងវិធាន៦៣.៣ នៃវិធានផ្ទៃក្នុង ដែលនៅតែត្រូវបានបំពេញគ្រប់គ្រាន់ដដែល និងដែលបានបញ្ជាក់ថាការបន្តថិរវេលានៃការឃុំខ្លួនមួយឆ្នាំទៀតគឺជាការត្រឹមត្រូវ។

*ក. មូលហេតុដែលត្រូវបានរកឃើញនិងជឿជាក់យ៉ាងច្បាស់-វិធាន៦៣.៣.ក*

៣៥. ក្នុងសំណុំរឿងថ្ងៃនេះ មានភស្តុតាងដែលអាចបំពេញបានគ្រប់គ្រាន់ តាមលក្ខខណ្ឌតម្រូវរបស់អ្នកសង្កេតការណ៍ឯករាជ្យនៅក្នុងដំណាក់កាលនៃការស៊ើបសួរនេះ ដែលថាដើមបណ្តឹងឧទ្ធរណ៍អាចបានប្រព្រឹត្តឧក្រិដ្ឋកម្មផ្សេងៗ ដែលបច្ចុប្បន្ននេះគាត់កំពុងតែស្ថិតនៅក្រោមការស៊ើបសួរ។

៣៦. នៅក្នុងបណ្តឹងឧទ្ធរណ៍ មេធាវីការពារក្តីមិនបានដាក់នូវសំអាងនានាដែលពាក់ព័ន្ធផ្អែកលើមូលដ្ឋាននៃវិធាន៦៣.៣.ក នៃវិធានផ្ទៃក្នុងទេ។ តាមពិត មេធាវីការពារក្តីមិនបានធ្វើការតវ៉ាប្រឆាំងនឹងអត្ថិភាពនៃមូលហេតុដែលត្រូវបានរកឃើញនិងជឿជាក់យ៉ាងច្បាស់ថាជនត្រូវចោទអាចបានប្រព្រឹត្តបទឧក្រិដ្ឋដូចដែលបានកំណត់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរនោះទេ សូម្បីតែជាប្រយោល និងមិនបានយោងទៅលើភស្តុតាងណានោះទេ[70]។

៣៧. ហេតុដូចនេះ សហព្រះរាជអាជ្ញា យល់ឃើញថាជាការចាំបាច់គ្រាន់តែលើកឡើងបញ្ជាក់អំពីធាតុផ្សំថ្មីៗ ក្រោមវិធាន៦៣.៣.ក នៃវិធានផ្ទៃក្នុង ដែលបានអន្តរាគមន៍ចាប់តាំងពីពេលចាប់ខ្លួនដើមបណ្តឹងឧទ្ធរណ៍មកតែប៉ុណ្ណោះបានហើយ។ ចំណែកឯភស្តុតាងដែលគាំទ្រដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ដែលភស្តុតាងទាំងនោះមានលក្ខណៈគ្រប់គ្រាន់ដោយខ្លួនឯងសម្រាប់បញ្ជាក់ពីភាពត្រឹមត្រូវនៃលក្ខណៈវិនិច្ឆ័យសម្រាប់ "មូលហេតុដែលត្រូវបានរកឃើញនិងជឿជាក់យ៉ាងច្បាស់" នោះ សហព្រះរាជអាជ្ញា បានដាក់បញ្ចូលក្នុងនោះដោយការយោងទៅលើដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរដូចមាននៅក្នុងកថាខណ្ឌទី១៨ ដល់កថាខណ្ឌទី២៤ នៃ "ចម្លើយតបទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៨ " របស់ខ្លួន[71]។

[70] នៅក្នុងបណ្តឹងឧទ្ធរណ៍របស់ពួកគាត់, ឯកសារលេខ C20/5/1, ក្នុងខណៈពេលដែលត្រូវលើកឡើងអំពីភស្តុតាងដែលមានស្រាប់នៅក្នុងសំណុំរឿងមិនលើកទេ ពួកគាត់បែរជាគ្រាន់តែរិះគន់អំពីអង្គហេតុដែលថានៅក្នុងដីកាបន្តការឃុំខ្លួនមានការចោទប្រកាន់ជាលក្ខណៈទូទៅផ្សេងៗដោយគ្មានការផ្តល់សក្ខីកម្មអំពីប្រភពសម្រាប់បញ្ជាក់អះអាងនោះទៅវិញ (កថា ខណ្ឌទី១៦-១៧) ថា នៅក្នុងដីកាបន្តការឃុំខ្លួនមានពត៌មានដែលមិនត្រឹមត្រូវ(ដោយឯកសារពីរដែលបានលើកឡើង ដោយសហចៅ ក្រមស៊ើបអង្កេតនោះ គឺវាមិនជាប់ទាក់ទងគ្នាទេ-កថាខណ្ឌទី១៨-២០), ថា សហចៅក្រមស៊ើបអង្កេតបានខកខានមិនបានប្រមែរប្រមូលភស្តុតាងដាក់បន្ទុកប្រឆាំងនឹងដើមបណ្តឹងឧទ្ធរណ៍នោះទេដែលនេះគឺជាការគាំទ្រដោយផ្ទាល់ដល់បទចោទផ្សេងៗប្រឆាំងនឹងរូបគាត់ (កថាខណ្ឌទី៣៣,៣៦, ៣៨ និង៣៩ នៃបណ្តឹងឧទ្ធរណ៍)។ សូមអានមតិអធិប្បាយនៅក្នុងចម្លើយតបនេះ អំពីទឡ្ហីករណ៍មួយចំនួនក្នុងចំណោមទឡ្ហីករណ៍ទាំងនោះ, ដូចខាងលើក្នុងកថាខណ្ឌទី៨-១០ និងទី២៩។

[71] *ករណីរឿងរបស់ អៀង ធីរិទ្ធ*, ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធប្រឆាំង នឹងដីកាសម្រេចឃុំខ្លួនបណ្តោះសន្ន ចុះថ្ងៃទី១៤វិច្ឆិកា ២០០៧ និងថ្ងៃទី២១ មករា ២០០៨, ឯកសារលេខ C20/1/7, ERN 00186408-34 (ភាសាអង់គ្លេស)។

៣៨. កាលពីថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០០៨ នៅក្នុងដីកាសម្រេចបន្តថិរវេលារបស់ខ្លួនដែលមានការដេញដោល សហចៅក្រមស៊ើបអង្កេតបានធ្វើការកត់សំគាល់ថា "មូលហេតុដែលត្រូវបានរកឃើញនិងជឿជាក់យ៉ាងច្បាស់" បានបន្តមានអត្ថិភាពសម្រាប់ធ្វើឲ្យពួកខ្លួនជឿថា ជនត្រូវចោទអាចបានប្រព្រឹត្តបទឧក្រិដ្ឋ ដូចដែលបានកំណត់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ។ សហចៅក្រមស៊ើបអង្កេត បានរំលឹកឡើងវិញថា អ.ប.ជ នៅក្នុងដីកាសម្រេចរបស់ខ្លួនចុះថ្ងៃទី៩ ខែតុលា ឆ្នាំ២០០៨ បានទទួលភារៈក្នុងការធ្វើវិភាគលំអិតមួយទៅលើសំណុំរឿង ហើយបានរកឃើញថាមានភស្តុតាងគ្រប់គ្រាន់សម្រាប់បំពេញតាមលក្ខខណ្ឌតម្រូវរបស់អ្នកសង្កេតការណ៍ឯករាជ្យ ដែលថាជនត្រូវចោទអាចបានប្រព្រឹត្តបទឧក្រិដ្ឋទាំងឡាយដូចដែលបានចោទប្រកាន់[72]។ សហចៅក្រមស៊ើបអង្កេត ក៏បានធ្វើការកត់សំគាល់ផងដែរថា កិច្ចស៊ើបសួរមានដំណើរការជឿនលឿន ចាប់តាំងពីសវនាការលើបណ្តឹងឧទ្ធរណ៍ស្តីពីការឃុំខ្លួនចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៨ មក ដោយសារតែឯកសារជាភស្តុតាងបន្ថែមត្រូវបានប្រមូលរួច[73]។

៣៩. សហព្រះរាជអាជ្ញា ស្នើជាយោបល់ថា អ.ប.ជ គួរតែបញ្ជាក់អះអាងបន្ថែមពីការរកឃើញពីមុនៗមករបស់ខ្លួន អំពីអត្ថិភាពនៃមូលហេតុដែលត្រូវបានរកឃើញនិងជឿជាក់យ៉ាងច្បាស់ថា ជនត្រូវចោទអាចបានប្រព្រឹត្តបទឧក្រិដ្ឋទាំងឡាយដូចដែលបានចោទប្រកាន់[74]។ ជាការបង្ហាញឲ្យឃើញយ៉ាងច្បាស់បន្ទាប់ពីការពិនិត្យសារឡើងវិញមួយទៅលើសំណុំរឿងថា មូលដ្ឋាននៃការជឿជាក់នេះ ក្នុងពេលបច្ចុប្បន្នគឺវាកាន់តែខ្លាំងជាងកាលពីមួយឆ្នាំកន្លងមកនោះទៅទៀត ដោយសារតែភស្តុតាងដែលដាក់បន្ទុកទៅលើដើមបណ្តឹងឧទ្ធរណ៍មានការកើនឡើង ទាំងទំហំ និងទាំងស្ថានទម្ងន់ នៅក្នុងប៉ុន្មានខែថ្មីៗនេះ។ សហចៅក្រមស៊ើបអង្កេតបានចេញដីកាចាត់ឲ្យស៊ើបសួរជំនួសចំនួន យ៉ាងហោចណាស់ក៏ដប់បី(១៣)ដែរ នៅក្នុងសំណុំរឿងលេខ

---

[72] សាលដីកាសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ ប្រឆាំងនឹងការឃុំខ្លួន ឯកសារលេខ C20/1/26, កថាខណ្ឌទី៥១។

[73] ដីកាសម្រេចបន្តការឃុំខ្លួន C20/4, កថាខណ្ឌទី១៣-២០។

[74] នៅក្នុងសាលដីកាសម្រេចរបស់ខ្លួនលើបណ្តឹងឧទ្ធរណ៍របស់អៀង ធីរិទ្ធ ប្រឆាំងនឹងការឃុំខ្លួនបណ្តោះអាសន្ន អ.ប.ជ បានកត់សំគាល់ថា ពាក្យថា "បានប្រព្រឹត្ត" ត្រូវតែយល់ថា គឺវាមានន័យថា "ជាប់ជំពាក់ទៅនឹងការទទួលខុសត្រូវជាបុគ្គលចំពោះ " ដែលរួមមាន ការរៀបចំផែនការ, ការញុះញង់, ការបញ្ជា, ការជួយឧបត្ថម្ភនិងជ្រោមជ្រែង ឬ ការប្រព្រឹត្ត, ហើយនិង ការទទួលខុសត្រូវរបស់ថ្នាក់លើ។ ករណីរឿងរបស់ អៀង សារី សាលដីកាសម្រេចរបស់អ.ប.ជ លើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួន អៀង សារី បណ្តោះអាសន្ន ឯកសារលេខ C22/1/73, ERN 00232830-61 (ភាសាអង់គ្លេស), កថាខណ្ឌទី៧១។

០០២ (ឯកសារលេខ D25, D40, D43, D78, D82, D91, D92, D93, D94, D104, D107, D115 និង D123 )[75] និងសហចៅក្រមស៊ើបអង្កេត ឬអ្នកស៊ើបអង្កេតរបស់ខ្លួនបានធ្វើសម្ភាសន៍សាក្សីចំនួនជាងមួយរយនាក់ ទាក់ទងទៅនឹងឧក្រិដ្ឋកម្មទាំងឡាយដែល ជនទាំងប្រាំរូបត្រូវបានចោទប្រកាន់ នៅក្នុងសំណុំរឿងនោះដែលក្នុងនោះរួមទាំងដើមបណ្តឹង ឧទ្ធរណ៍ផង អាចបានប្រព្រឹត្ត[76]។ ជាបន្ថែមពីលើនេះ អ្វីសំខាន់ដែលមាននៅក្នុងសំណុំរឿងលេខ ០០១ ដែលភាគច្រើនពាក់ព័ន្ធទៅនឹងករណីរឿងរបស់ដើមបណ្តឹងឧទ្ធរណ៍ ត្រូវបានផ្ទេរទៅក្នុងសំណុំរឿងលេខ០០២ រួចហើយ ដោយកំណត់មួយរបស់សហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០០៨[77]។ កំណត់ហេតុសួរចម្លើយ កាំង ហ្គេកអ៊ាវ ហៅ ឌុច ចំនួន២៨ ដែលបានធ្វើឡើងក្នុងបរិបទនៃសំណុំរឿងលេខ ០០១ ត្រូវបានសហចៅក្រមស៊ើបអង្កេតដាក់បញ្ចូលទៅក្នុងសំណុំរឿងលេខ ០០២ កាលពីថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០០៨រួចហើយ[78]។ លើសពីនេះ (បានលុបចេញ)[79]។

---

[75] ក្នុងចំណោមដីកាចាត់ឲ្យស៊ើបសួរជំនួសទាំងនោះ មានដីកាចំនួន៧ ទាក់ទងទៅនឹងការធ្វសម្ភាសន៍សាក្សី: ឯកសារលេខ D25 (ការធ្វើសម្ភាសន៍សាក្សី៣៦នាក់), ឯកសារលេខ D40 (ការធ្វើសម្ភាសន៍សាក្សី២៥នាក់), ឯកសារលេខ D91 (ការធ្វើសម្ភាសន៍សាក្សី២៤នាក់), ឯកសារលេខ D92 (ការធ្វើសម្ភាសន៍សាក្សី៨នាក់), ឯកសារលេខ D94 (ការធ្វើសម្ភាសន៍សាក្សី១៦នាក់), ឯកសារលេខ D107 (ការធ្វើសម្ភាសន៍សាក្សី១នាក់យ៉ាងតិច) ឯកសារលេខ D115 (បានលុបចេញ) និង D123 (ការធ្វើសម្ភាសន៍សាក្សី៣នាក់) ដែលមានចំនួនសរុបយ៉ាងតិច ១១៨នាក់ ដែលបានដាក់នៅក្នុងសំណុំរឿង ។ ក៏ប៉ុន្តែ តាមសហចៅក្រមស៊ើបអង្កេត មានដីកាចាត់ឲ្យស៊ើបសួរជំនួសជាច្រើនដែលកំពុងតែត្រូវបានអនុវត្ត ។ គឺមិនមានអ្វីគួរឲ្យភ្ញាក់ផ្អើលទេដោយសារតាមធម្មតាភាគីនានា ត្រូវបានគេផ្តល់ពត៌មាន - តែជាអកុសល - ត្រូវបានគេផ្តល់ពត៌មានអំពីដីកាចាត់ឲ្យស៊ើបសួរជំនួសទាំងនោះ នៅពេលដែលដីកាទាំងនោះត្រូវបានអនុវត្តចប់សព្វគ្រប់រួចទៅហើយ ។ គឺបានន័យថា តាមការពិតមានភវនីយភាពយ៉ាងខ្ពស់ថា មានចម្លើយច្រើនជានេះឆ្ងាយណាស់ដែលសហចៅក្រមស៊ើបអង្កេតប្រមូលបាន ចាប់តាំងពីបទសម្ភាសន៍សាក្សីទាំង១១៥នេះត្រូវបានដាក់បញ្ចូលទៅក្នុងសំណុំរឿងរួចមក ។ សហព្រះរាជអាជ្ញាសូមជំរុញលើកទឹកដល់ការអនុវត្តក្នុងការដាក់ចម្លើយសាក្សីភ្លាមៗតាមដែលអាចធ្វើទៅបាននៅក្នុងសំណុំរឿង នៅមុនពេលដែលរបាយការណ៍ស្តីពីការអនុវត្តដីកាបញ្ជូនរឿងឲ្យស៊ើបសួរត្រូវបានចប់សព្វគ្រប់ ។

[76] ក្នុងពេលឥឡូវនេះដែលដីកាដំណោះ លើសំណុំរឿងលេខ១ ស្រាយត្រូវបានចេញរួចហើយ គេទន្ទឹងចងបានឲ្យណើរការនៃកិច្ចស៊ើបសួរនឹងមានសន្ទុះលឿនយ៉ាងខ្លាំងនៅក្នុងពេលអនាគតដ៏ខ្លីខាងមុខនេះ។

[77] *ករណីរឿងរបស់ នួន ជា និងជនដទៃទៀត*, កំណត់សំគាល់ដោយសហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី២៨ តុលា ២០០៨, ឯកសារលេខ D108, ERN 00236076-77 (ភាសាអង់គ្លេស) និង ឧបសម្ព័ន្ធភ្ជាប់នឹងកំណត់សំគាល់នេះ លេខ D108/1។

[78] *ករណីរឿងរបស់ នួន ជា និងជនដទៃទៀត*, កំណត់សំគាល់ដោយសហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី៣០ ឧសភា ២០០៨, ឯកសារលេខ D86, ERN 00194661-67 (ភាសាអង់គ្លេស) ។

[79] (បានលុបចេញ)

៤០. សហព្រះរាជអាជ្ញា ក៏បានចូលរួមចំណែកដល់ការស៊ើបសួរផងដែរ ដោយការដាក់ឯកសារភស្តុតាងមួយចំនួនធំចាប់តាំងពីពេលដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ និងពីពេលចាប់ខ្លួនដើមបណ្តឹងឧទ្ធរណ៍មក[80]។ គួររំលឹកឡើងវិញថា ភស្តុតាងទាំងឡាយដែល សហចៅក្រមស៊ើបអង្កេត បានដាក់បញ្ចូលនៅក្នុងសំណុំរឿងតាមសំណើរបស់ សហព្រះរាជអាជ្ញា (គឺដីកាបញ្ជូនរឿងឲ្យស៊ើបសួរនិងការដាក់ជូនជាបន្តបន្ទាប់មកទៀត) ក៏ដូចជាភស្តុតាងដែលប្រមូលបានកាលពីឆ្នាំមុន ដោយសហចៅក្រមស៊ើបអង្កេត គឺគ្របដណ្តប់គ្រប់ទម្រង់និងប្រភេទទាំងអស់នៃការចូលរួមចំណែករបស់ដើមបណ្តឹងឧទ្ធរណ៍ នៅក្នុងបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលត្រូវបានចោទប្រកាន់ រួមមាន ភស្តុតាងពីទីកន្លែងកើតហេតុ, ភស្តុតាងដែលផ្សារភ្ជាប់ទីកន្លែងកើតហេតុទៅនឹងរចនាសម្ព័ន្ធមេដឹកនាំដែលនៅក្នុងនោះ ដើមបណ្តឹងឧទ្ធរណ៍បានអនុវត្តនូវសិទ្ធិអំណាចក្នុងការបញ្ជា, ភស្តុតាងដែលគាំទ្រអំពីការចូលរួមរបស់គាត់នៅក្នុងសហកម្មឧក្រិដ្ឋកម្មរួម ព្រមទាំងភស្តុតាងដែលគាំទ្រធាតុផ្សំខាងយុត្តាធិការ ដូចជា ការវាយប្រហារដែលមានលក្ខណៈជាទូទៅនិងជាប្រព័ន្ធ ប្រឆាំងនឹងប្រជាជនស៊ីវិល។

៤១. (បានលុបចេញ)[81][82][83]។

៤២. (បានលុបចេញ)[84][85][86][87][88]។

---

[80] (បានលុបចេញ)

[81] (បានលុបចេញ)

[82] (បានលុបចេញ)

[83] (បានលុបចេញ)

[84] (បានលុបចេញ)

[85] (បានលុបចេញ)

[86] (បានលុបចេញ)

[87] (បានលុបចេញ)

[88] (បានលុបចេញ)

00274039



៤៣. (បានលុបចេញ) [89] [90]។

៤៤. ជាចុងក្រោយ គេត្រូវតែលើកឡើងបញ្ជាក់ថា នៅក្នុងពេលដែលជនត្រូវចោទដទៃៗទៀតបានដាក់សំណើសុំឱ្យមានការស៊ើបសួរនោះ ដើមបណ្តឹងឧទ្ធរណ៍មិនមានដាក់សំណើទេ។ អាស្រ័យហេតុនេះ ការតវ៉ាជំទាស់របស់ដើមបណ្តឹងឧទ្ធរណ៍ អំពីការគ្មានការជឿនលឿនទៅមុខ គឺមិនមានមូលដ្ឋានច្បាស់លាស់ទេ ហើយគួរតែត្រូវបានបដិសេធចោល។ មិនឃើញមានភស្តុតាងដោះបន្ទុកណាដែលមានសារៈសំខាន់ដែលអាចលប់លើការសម្រេចអំពី "អត្ថិភាពនៃមូលហេតុដែលត្រូវបានរកឃើញនិងជឿជាក់យ៉ាងច្បាស់" នោះទេ។ មកទល់ថ្ងៃនេះ ដើមបណ្តឹងឧទ្ធរណ៍មិនបានដាក់ឯកសារណាមួយដែលជាឯកសារភស្តុតាង ដើម្បីដោះបន្ទុកដែលតិចជាងនេះនៅក្នុងសំណុំរឿង ដែលជម្រុញឱ្យគួរតែធ្វើការពិនិត្យពិចារណាឡើងវិញទៅលើការសម្រេចនេះទេ។

*ខ. ការឃុំខ្លួនបណ្តោះអាសន្នស្ថិតនៅជាវិធានការមួយដ៏ចាំបាច់ដដែល*

៤៥. ដើមបណ្តឹងឧទ្ធរណ៍មិនបានកំណត់អត្តសញ្ញាណ អំពីមានការផ្លាស់ប្តូរកាលៈទេសៈជាក់ស្តែងណាមួយ ដើម្បីបង្ហាញឱ្យឃើញថាលក្ខណៈដែលតម្រូវចាំបាច់ឱ្យឃុំខ្លួនរូបគាត់ក្រោម វិធាន ៦៣.៣.ខនោះ មិនត្រូវបានបំពេញគ្រប់គ្រាន់ទៅតាមលក្ខខណ្ឌតម្រូវតទៅទៀតហើយ ។ ការសម្រេចរបស់ អ.ប.ជ កាលពីថ្ងៃទី៩ ខែកក្កដា ឆ្នាំ២០០៨ ថា ការឃុំខ្លួនបណ្តោះអាសន្នគឺជាការចាំបាច់ ត្រូវបានចេញក្រោយពីបានពិនិត្យមើលឡើងវិញ ទៅលើរាល់ភស្តុតាងទាំងអស់ ហើយបន្ទាប់មកទៀត ទៅលើសំណុំរឿង ។ ដើមបណ្តឹងឧទ្ធរណ៍គ្មានបានផ្តល់នូវភស្តុតាងថ្មីទេ ចាប់តាំងពីថ្ងៃទី៩ ខែកក្កដា ឆ្នាំ២០០៨មក ដើម្បីអាចធ្វើឱ្យ អ.ប.ជ ត្រូវតែធ្វើការផ្លាស់ប្តូរ (ការសម្រេច) ទៅលើអ្វីដែលបានរកឃើញនេះទេ។ សហព្រះរាជអាជ្ញា ជូនសេចក្តីសន្និដ្ឋាន

---

[89] (បានលុបចេញ)

[90] (បានលុបចេញ)

ថា សន្និទានភាពដែលបានគូសបញ្ជាក់ដោយសង្ខេប នៅក្នុងសាលដីកាសម្រេចលើបណ្តឹងឧទ្ធរណ៍ស្តីពីការឃុំខ្លួន នៅមានសុពលភាពនៅឡើយក្នុងពេលបច្ចុប្បន្ននេះ ដែលគួរតែត្រូវបានគោរពតាម។

៤៦. ជាងនេះទៅទៀត មេធាវីការពារក្តីមិនបានតវ៉ាជំទាស់ អំពីអត្ថិភាពនៃលក្ខខណ្ឌជាជំនួស ឬលក្ខខណ្ឌដាច់ដោយឡែកពីគ្នានៃវិធាន ៦៣.៣.ខ នៃវិធានផ្ទៃក្នុង ដើម្បីនឹងសម្រេចថា តើការឃុំខ្លួនបណ្តោះអាសន្នគឺជាវិធានការដ៏ចាំបាច់ដែរ ឬទេ ដើម្បី (២) ថែរក្សាភស្តុតាង ឬទប់ស្កាត់កុំឱ្យបំផ្លាញភស្តុតាង, (៣) ធានាអំពីវត្តមានរបស់ចុងចោទនៅក្នុងពេលដំណើរការនីតិវិធី, ឬ (៥) រក្សាសណ្តាប់ធ្នាប់សាធារណៈ ។ អាស្រ័យហេតុនេះ សហព្រះរាជអាជ្ញាដាក់បញ្ចូលដោយយោងទៅលើដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ដូចមាននៅក្នុងកថាខណ្ឌចាប់ពីទី៣១ ដល់ទី៤៩ នៅក្នុង "ចម្លើយតបទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាសម្រេចស្តីពីការឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៧"របស់ខ្លួន[91] ។ មេធាវីការពារក្តីគ្រាន់តែលើកសំអាងថា សហចៅក្រមស៊ើបអង្កេត ខកខានមិនបានផ្តល់ការវែកញែកហេតុផលណាមួយនៅក្នុង ដីកាសម្រេចបន្តការឃុំខ្លួន តែមួយប៉ុណ្ណោះ ដែលបញ្ជាក់ថាមាន "ហានិភ័យពិតប្រាកដមែន" ថាសាក្សីទាំងឡាយអាចនិងប្រកែកមិនព្រមចូលរួមនៅក្នុងដំណើរការនីតិវិធី[92] (វិធាន ៦៣.៣.ខ.១) ។

៤៧. ទី១ ឧប្បត្តិហេតុពាក់ព័ន្ធមួយចំនួនបានកើតឡើងនៅក្នុងសវនាការនានារបស់ អ.ប.ជ ចុះថ្ងៃទី ២១ ខែឧសភា ឆ្នាំ២០០៨ និង ថ្ងៃទី៩ ខែកក្កដា ឆ្នាំ២០០៨ ។ ដូចបានលើកឡើងខាងលើ អាកប្បកិរិយារំលោភបំពានរបស់ជនត្រូវចោទនៅក្នុងពេលសវនាការទាំងនោះ គឺមានលក្ខណៈជាការគម្រាមកំហែង និងប៉ុនប៉ងក្នុងការបំភិតបំភ័យចំពោះភាគីនានា និង/ឬចំពោះចៅក្រមដែលជាធាតុផ្សំមួយចំនួន ដែលត្រូវយកចិត្តទុកដាក់ក្នុងពេលដែលធ្វើការវាយតម្លៃអំពី ហានិ

---

[91] ករណី អៀង ធីរិទ្ធ ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងឧទ្ធរណ៍ស្តីពីដីកាឃុំខ្លួនបណ្តោះអាសន្ន កាលពីថ្ងៃទី ១៤-វិច្ឆិកា-២០០៧ ចុះថ្ងៃទី ២១-មករា-២០០៨ C 20/I/7, ERN 00186408-34 (ភាសាអង់គ្លេស) ។

[92] ប្រតិចារឹក ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៨, ច្បាប់ជាភាសាបារាំង, ERN 00220017-48 (ភាសាបារាំង), ត្រង់ ERN 00220034, បន្ទាត់ទី៧ ដែលអាចបកប្រែជាភាសាអង់គ្លេសថា "ជនត្រូវចោទរំខានដល់សវនាការ" ។

ភ័យផ្សេងៗដែលអាចនឹងបង្កឡើងដោយសារការគាបសង្កត់ ដែលដើមបណ្ដឹងឧទ្ធរណ៍អាចនឹងធ្វើឡើងប្រឆាំងនឹងសាក្សី និងជនរងគ្រោះនានា (វិធាន៦៣.៣.ខ.១), ប្រឆាំងនឹង ការថែរក្សាភស្តុតាង (វិធាន៦៣.៣.ខ.២) និងការរក្សាសណ្ដាប់ធ្នាប់សាធារណៈ (វិធាន ៦៣.៣.ខ.៥) ។ អាកប្បកិរិយានេះ ក៏អាចប៉ះពាល់ផងដែរទៅដល់សន្តិសុខផ្ទាល់ខ្លួនរបស់ដើមបណ្ដឹងឧទ្ធរណ៍ បើសិនជាអាកប្បកិរិយាបែបនេះ ត្រូវបានធ្វើឡើងវិញជាថ្មីម្ដងទៀតជាសាធារណៈ ពេលត្រូវបានដោះលែង (វិធាន៦៣.៣.ខ.៤) ។ ឧប្បត្តិហេតុទាំងនេះអាចត្រូវបានរៀបរាប់ដូចខាងក្រោមនេះ នៅក្នុងកថាខណ្ឌពីទី៤៨ ដល់ទី៤៩ ។

៤៨. (បានលុបចេញ)[93] [94] [95] [96] [97] [98] [99] [100] [101] [102] [103] ។

៤៩. កាលពីថ្ងៃទី៩ ខែកក្កដា ឆ្នាំ២០០៨ នៅក្នុងសវនាការមួយរបស់ អ.ប.ជ ប្រធានអង្គសវនាការបានអានខ្លាំងៗនូវ "សាលដីកាសម្រេចលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចស្ដីពីការឃុំខ្លួនអៀង ធីរិទ្ធ បណ្ដោះអាសន្ន" របស់ អ.ប.ជ ។ នៅពេលចប់សវនាការ ជនត្រូវចោទបានស្រែកខ្លាំងៗដាក់ចៅក្រមតុលាការថាៈ *"ខ្ញុំមិនថានរណាជាអ្នកសរសេរសាលដីកាសម្រេចនេះ! ខ្ញុំមិនថានរណាហើយ!"* ។ ការធ្វើអន្តរាគមន៍នេះអាចនឹងត្រូវបានបកស្រាយថា គឺជាការប៉ុនប៉ងមួយធ្វើការគម្រាមកំហែង ឬសម្លុតបំភ័យមួយចំពោះចៅក្រមនានា និង/ឬ ចំពោះបុគ្គលិក

---

[93] (បានលុបចេញ)

[94] (បានលុបចេញ)

[95] (បានលុបចេញ)

[96] (បានលុបចេញ)

[97] (បានលុបចេញ)

[98] (បានលុបចេញ)

[99] (បានលុបចេញ)

[100] (បានលុបចេញ)

[101] (បានលុបចេញ)

[102] (បានលុបចេញ)

[103] (បានលុបចេញ)

នៃ អ.វ.ត.ក[104] ។ តែជាអកុសល រឿងនេះមិនត្រូវបានរាយការណ៍នៅក្នុងប្រតិចារិកនៃសវនាការនោះទេ ។

៥០. ឧប្បត្តិហេតុទាំងពីរលើកនេះ គួបផ្សំជាមួយនឹងអាកប្បកិរិយា និងសេចក្ដីថ្លែងការណ៍ជាសាធារណៈកន្លងមករបស់ដើមបណ្ដឹងឧទ្ធរណ៍ ដូចដែល អ.ប.ជ បានលើកឡើងបញ្ជាក់នៅក្នុងសាលដីកាសម្រេចលើបណ្ដឹងឧទ្ធរណ៍របស់ខ្លួន ចុះថ្ងៃទី៩ ខែកក្កដា ឆ្នាំ២០០៨[105] គឺជាការបង្ហាញឲ្យឃើញយ៉ាងច្បាស់អំពីហានិភ័យជាក់ស្ដែងថាជនត្រូវចោទអាចនិងធ្វើការគាបសង្កត់, សម្លុតបំភ័យ ឬ ជ្រៀតជ្រែកដល់សាក្សី ឬជនរងគ្រោះនានា បើសិនជាត្រូវដោះលែងជាបណ្ដោះអាសន្ន ។ ដើមបណ្ដឹងឧទ្ធរណ៍មានសិទ្ធិអាចពិនិត្យមើលឈ្មោះសាក្សីសំខាន់ៗជាគន្លឹះបាន ។ ដែលសាក្សីទាំងនោះភាគច្រើន មកទល់ពេលនេះមិនទាន់ត្រូវបាន សហចៅក្រមស៊ើបអង្កេតស្ដាប់ចម្លើយនៅឡើយទេ នៅក្នុងដំណាក់កាលនៃការស៊ើបសួរនេះ ។ ផ្អែកតាមនេះ ហានិភ័យដែលថា គាត់នឹងអាចប្រើឥទ្ធិពលទៅលើសាក្សីដើម្បីឲ្យភ័យខ្លាច លែងហ៊ានផ្ដល់សក្ខីកម្មនៅចំពោះមុខ អ.វ.ត.ក គឺមានភាពកាន់តែធំជាងមុនទៅទៀត ។

៥១. លើសពីនេះ បើសិនជាត្រូវបានដោះលែងនោះ គឺមានហានិភ័យជាក់ស្ដែងមួយថា ដើមបណ្ដឹងឧទ្ធរណ៍មុខជានឹងបន្តធ្វើនូវសេចក្ដីថ្លែងការណ៍ដែលមានលក្ខណៈរំលោភបំពាន (Offensive) បែបនេះ នៅក្នុងបណ្ដាញផ្សព្វផ្សាយព័ត៌មានសាធារណៈនានាដែលអាចមានផលប៉ះពាល់ដែលមិន

---

[104] *ករណីរបស់ អៀង ធីរិទ្ធ,* សាលដីការបស់ អ.ប.ជ លើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្នជនត្រូវចោទ អៀង ធីរិទ្ធ, C 20/I/26, ERN 00201588-604 (ជាភាសាអង់គ្លេស) ។ ជាថ្មីម្ដងទៀត ការដកស្រង់សំដីនេះឆ្លុះបញ្ចាំងពីអ្វីដែលសហព្រះរាជអាជ្ញាចាំបានលើសំដីរបស់ជនត្រូវចោទដែលបាននិយាយ ។

[105] សាលដីការបស់ អ.ប.ជ លើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្នជនត្រូវចោទ អៀង ធីរិទ្ធ, C 20/I/26, ERN 00201588-604 (ភាសាអង់គ្លេស), កថាខ័ណ្ឌទី៤៩-៥០ ។ អៀង ធីរិទ្ធ បានជេរប្រមាថ និងប៉ន់ប៉ងបំភ័យ ឆាំង យុះ លិខិតដែលបានបញ្ជូនចេញនៅថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ១៩៩៩ ដោយអៀង ធីរិទ្ធ ផ្ញើជូន Chris Decherd, ដែលបានបោះពុម្ពផ្សាយក្រោមចំណងជើងថា "អៀង ធីរិទ្ធ និយាយថា គាត់គ្រាន់តែចង់បំរើប្រជាជនរបស់គាត់តែប៉ុណ្ណោះ", *The Cambodia Daily,* ថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ ១៩៩៩, ERN 00000588-589 (ភាសាអង់គ្លេស) ។ គេបានរាយការណ៍ឲ្យដឹងថា ជនត្រូវចោទបានអំពាវនាវឲ្យប្រជាជនបំបិទមាត់ មីម៉ក់ នៅក្នុងកិច្ចប្រជុំមួយរបស់ចលនារួបរួមជាតិប្រជាធិបតេយ្យ (DNUM) នៅក្នុងឆ្នាំ២០០៣៖ "ក្រុមហ៊ុនសារជីវកម្មខ្មែរក្រហមៈ អតីតជនកុម្មុយនីស្ត ក្រសោបយកសេដ្ឋកិច្ចទីផ្សារនៅស្រុកម៉ាឡៃ" *The Cambodia Daily,* ថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០០៧, ERN 00106073-78 ។

គ្រាន់តែបំភិតបំភ័យសាក្សីនិងជនរងគ្រោះតែប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងធ្វើឱ្យខូចដល់សណ្តាប់ធ្នាប់សាធារណៈ ហើយជាផលវិបាកនោះ គឺជាការបង្កើតឡើងនូវហានិភ័យចំពោះសុវត្ថិភាពផ្ទាល់ខ្លួនរបស់រូបគាត់ផងដែរ ។

៥២. ទី២ ចំពោះការគំរាមកំហែងដែលបង្កឡើងចំពោះសណ្តាប់ធ្នាប់សាធារណៈ និងសន្តិសុខផ្ទាល់ខ្លួនរបស់គាត់ - វិធាន៦៣.៣.ខ.៤ និង៥ សេចក្តីថ្លែងការណ៍ថ្មីៗនេះ និងអាកប្បកិរិយារបស់ជនរងគ្រោះ និងដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួន បានបង្ហាញឱ្យឃើញថា ការដោះលែងជនណាម្នាក់ក្នុងចំណោមជនត្រូវចោទទាំងប្រាំ(៥) រូបនេះ អាចនឹងធ្វើឱ្យប្រែក្លាយទៅជាអំពើហឹង្សាសំដៅប្រឆាំងចំពោះអតីតមេដឹកនាំខ្មែរក្រហមទាំងនោះ រួមទាំងដើមបណ្តឹងឧទ្ធរណ៍, ក្រុមមេធាវីការពារក្តី ឬ អ.វ.ត.ក ផង ។ នៅក្នុងអត្ថបទមួយនៃកាសែត The New York Times បានសរសេរថា កាលពីថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០០៨[106] មានជនរងគ្រោះពីរនាក់បាននិយាយថា ពួកគេ រៀងៗខ្លួន ចង់តែ “ហាន់ (នួន ជា) ឱ្យទៅជា ជំរាកៗ ហើយរោយអំបិលទៅលើស្នាមរបួសរបស់គាត់ (...) វាយគាត់ និង ធ្វើទារុណកម្មគាត់ ហើយនិងដាក់គាត់ឱ្យខ្សែភ្លើងឆក់ដើម្បីធ្វើឱ្យគាត់ឆ្លើយ” ហើយឱ្យពួកគាត់ (ជនត្រូវចោទ) “ទទួលរងនូវការឈឺចាប់ដូចកាលពីពេលខ្ញុំឈឺចាប់នោះដែរ” ដូចជា “មានតែសម្លាប់គាត់ទេទើបធ្វើឱ្យខ្ញុំស្ងប់ចិត្តបាន”។ មានមនុស្សបីនាក់បានពោលដដែលៗនូវសំដី/ពាក្យគម្រាមកំហែងទាំងនោះ (មិនគ្រាន់តែប្រឆាំងនឹង ខៀវ សំផន និងក្រុមមេធាវីការពារក្តីរបស់គាត់តែប៉ុណ្ណោះទេ ក៏ប៉ុន្តែប្រឆាំងនឹងតុលាការផងដែរ) នៅក្នុងសន្និសីទសារព័ត៌មានមួយដែលធ្វើឡើងនៅពេលបន្ទាប់ពីសវនាការរបស់ អ.ប.ជ កាលពីថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០០៨[107] ។ ការសំដែងប្រតិកម្មដោយរំជួលចិត្តទាំង

[106] “នៅក្នុងសវនាការជំនុំជម្រះក្តីខ្មែរក្រហម ជនរងគ្រោះនឹងមិនមែនចូលរួមទ្រទ្រង់ដោយឥតបានការនោះទេ”, The New York Time, Seth Mydans, ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០០៨, អាចរកបានតាមរយៈវ៉ិបសាយ: http://www.nytimes.com/2008/06/17/world/asia/17cambodia.html?scp=1&sq=Seth%20Mydans%20in%20Khmer%20Rouge%20Trial%20Victims&st=cse នៅថ្ងៃទី៤ ខែមករា ឆ្នាំ២០០៩, (**ឧបសម្ព័ន្ធ ខ - ឯកសារភ្ជាប់ លេខ២**) ។

[107] នៅក្នុងខ្សែអាត់វីឌីអូ របស់ អ.វ.ត.ក អំពីសន្និសិទសារព័តមាន ចុះថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០០៨ (**ឧបសម្ព័ន្ធ ខ - ឯកសារភ្ជាប់ លេខ៣**) បានបង្ហាញពីស្ត្រីជាជនរងគ្រោះទីមួយនៃរបបខ្មែរក្រហមម្នាក់ បានស្រែកគំហក និងចង្អុលដាក់សហមេធាវីការពារក្តីខ្មែរ នៅក្នុងពេលសន្និសិទសារព័តមាន ។ លី មុន្នីសារ (Ly Monysar) ឥឡូវនេះ ជនរងគ្រោះជាឆ្នាំសន្តិសុខ បានគំរាមកំហែងតុលាការធ្វើឱ្យមានសកម្មភាពភេរវកម្មមួយប្រឆាំងនឹងមេដឹកនាំខ្មែរក្រហម “ប្រសិនបើតុលាការនៅតែគ្រាន់តែជាឆាកល្ខោនទេនោះ” នៅក្នុងពេលសន្និសិទចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹងបណ្តឹងឧទ្ធរណ៍របស់មេធាវីការពារក្តី អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាសម្រេចអំពីការបន្តថិរវេលានៃការឃុំខ្លួន

C20/5/7



នេះ គឺជារោគសញ្ញានៃជម្ងឺតានតឹងខាងផ្លូវអារម្មណ៍ក្រោយមានការប៉ះទង្គិចយ៉ាងធ្ងន់ធ្ងរខាងផ្លូវចិត្ត ដែលនៅតែមានជាបន្តនៅឡើយក្នុងចំណោមជនរងគ្រោះ ដោយដំណើរការនៃនីតិវិធីរបស់ អ.វ.ត.ក បាននាំឱ្យមានការលេចឡើងជាថ្មីនូវការថប់នៅក្នុងអារម្មណ៍[108] ។ អាស្រ័យហេតុនេះ ការគំរាមកំហែងជាសក្តានុពលចំពោះសណ្តាប់ធ្នាប់សាធារណៈ និងសន្តិសុខផ្ទាល់ខ្លួនគឺមិនមែនជាការគិតច្រឡំនោះទេ ក៏ប៉ុន្តែនៅតែមានភាពរស់រវើក និងជាក់ស្តែងនៅឡើយ ។

៥៣. អាស្រ័យហេតុនេះ សហព្រះរាជអាជ្ញា សូមស្នើដល់អង្គបុរេជំនុំជម្រះ សម្រេចថា លក្ខខណ្ឌនានានៃការឃុំខ្លួន តាមវិធាន៦៣.៣.ខ.១-៥ ត្រូវបានបំពេញ និងនៅតែបានបំពេញ ហេតុនេះជាការបញ្ជាក់ថាការបន្តឃុំខ្លួនដើមបណ្តឹងឧទ្ធរណ៍គឺជាការត្រឹមត្រូវ ។

### *គ. គ្មានដីកាសម្រេចឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការទេ*

---

សារព័តមានរបស់ជនរង គ្រោះ ហើយស្ត្រីជាដើមបណ្តឹងរដ្ឋប្បវេណីម្នាក់ (ដើមបណ្តឹងរដ្ឋប្បវេណី) ឈ្មោះ សុខ ជា បាននិយាយសារចុះសារឡើងថា បើសិនជាគាត់អាចចាប់ខៀវ សំផន បាននោះគាត់ចង់ "ស្ទុះទៅហែកស៊ីទាំងរស់" ។ សូមមើលផងដែរ "តុលាការខ្មែរក្រហម: l'exaspération des victims intensifiées par un clash avec la défense" ចុះថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០០៨, Ka-Set (site d'information sur le Cambodge), Stéphanie Gée, ដែលអាចរកបានវ៉ិបសាយ : http://ka-set.info/index2.php?option=com_content&task=view&id=783&pop=1&page=0&Itemid=46;"រឿងកំប្លុកកំប្លែងជួបយុត្តិធម៌បែបនៅសវនាការកាត់ក្តីខ្មែរក្រហម" *The Nation* (New York, USA), Barbara Crossette, ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០០៨, កថាខ័ណ្ឌទី៤ (**ឧបសម្ព័ន្ធ ខ - ឯកសារភ្ជាប់ លេខ៥**) ។ "តុលាការខ្មែរក្រហមបើកសវនាការលើបណ្តឹងឧទ្ធរណ៍ខៀវ សំផន ប្រឆាំងនឹងសេចក្តីសម្រេចអំពីករណីបកប្រែសំណុំរឿង" ចុះថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០០៨, ច្បាប់បកប្រែជាភាសាអង់គ្លេស, *រស្មីកម្ពុជា*, វ៉ុល១៦ លេខ៤៧៦០ (**ឧបសម្ព័ន្ធ ខ - ឯកសារភ្ជាប់ លេខ៦**) ។ ភាពគ្មានសណ្តាប់ធ្នាប់នៅក្នុងតុលាការ ខណៈដែលសវនាការបញ្ចប់ក្នុងភាពច្របូកច្របល់" " ចុះថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០០៨, *The Phnom Penh Post*, ដោយ Georgia Wilkins (**ឧបសម្ព័ន្ធ ខ - ឯកសារភ្ជាប់ លេខ7**) ។ "Le Cirque Vergès" ចុះថ្ងៃទី១១-១៧ ខែធ្នូ ឆ្នាំ២០០៨, *Cambodge Soir*, ដោយ Adrien Le Gal ។

[108] Rob Savage និយាយថា ការចាប់ផ្តើមសកម្មភាពតុលាការនៅចំពោះមុខ អ.វ.ត.ក "អាចធ្វើឱ្យមានហានិយភ័យថ្មីៗចំពោះសង្គមកម្ពុជា" ដែលអាច "នាំឱ្យមានការលេចឡើងជាថ្មីនូវការថប់នៅក្នុងអារម្មណ៍ និងផលវិបាកសង្គមជាអវិជ្ជមានដែលអាចនឹងអមមកជាមួយគ្នានោះ" ។ Rob Savage "ជម្ងឺតានតឹងខាងផ្លូវអារម្មណ៍ក្រោយមានការប៉ះទង្គិចយ៉ាងធ្ងន់ធ្ងរខាងផ្លូវចិត្តៈ មរតកនៃការឈឺចាប់និងអំពើហិង្សា", កាសែតប្រចាំខែរបស់ *South Eastern Globe*, ខែកក្កដា ឆ្នាំ២០០៧, ទំព័រ ២៤-២៧, ERN 00153657-61 (ភាសាអង់គ្លេស) ។

C20/5/7



៥៤. គ្មានដីកាសម្រេចឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ដែលនឹងមានលក្ខណៈម៉ឺង-មាត់ហ្មត់ចត់គ្រប់គ្រាន់ ដើម្បីបំពេញលើតម្រូវការចាំបាច់សម្រាប់ការពារសុវត្ថិភាពផ្ទាល់ខ្លួនរបស់ជនត្រូវចោទ ដើម្បីថែរក្សាសណ្តាប់ធ្នាប់សាធារណៈ និងដើម្បីរារាំងកុំឱ្យជនត្រូវចោទគាបសង្កត់ទៅលើសាក្សី និងជនរងគ្រោះ និងការពារមិនឱ្យបំផ្លាញភស្តុតាងបានឡើយ ។

## ៦. សេចក្តីសន្និដ្ឋាន

៥៥. អាស្រ័យហេតុនេះ សហព្រះរាជអាជ្ញា សូមស្នើដល់អង្គបុរេជំនុំជម្រះឱ្យ **បដិសេធចោល** បណ្តឹងឧទ្ធរណ៍របស់មេធាវីការពារក្តីទាំងមូល ។

ធ្វើនៅភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
នៅថ្ងៃទី២២ ខែមករា ឆ្នាំ២០០៨
**សហព្រះរាជអាជ្ញា**

| | |
|---|---|
| **លោក យ៉េត ចរិយា** | **លោក** Robert PETIT |
| **សហព្រះរាជអាជ្ញារង** | **សហព្រះរាជអាជ្ញា** |